**ការិយាល័យនិពន្ធ**
កាសែត " ខ្មែរប៉ុស្តិ៍ " ប្រចាំសហរដ្ឋអាមេរិក

**ឆ្នេរខាងលិច**
- មាជ សុវណ្ណារ៉ា
- គីម សារឿន
- ម៉ៅ ចិត្រា
- ភ៉ា នាថ
- សុភា ឫទ្ធិ
- មុី សម្ផស្ស
- ចាន់ កុសល
- សុវណ្ណារិទ្ធ

**ឆ្នេរខាងកើត**
- ពិន សំខុន
- សួន សេរី
- ម៉ម យិន
- គីម គឿន
- ឆន យ៉ុង

# ខ្មែរប៉ុស្តិ៍
# The khmer Post

**ទូរស័ព្ទពាណិជ្ជកម្មខ្មែរប៉ុស្តិ៍ ហ្វីឡាដែលហ្វីយ៉ា**
- សុមិន : (២៦៧) ២៥៣-៣៩៤៧
- ទូរស័ព្ទ នៅរ៉ូដអាយឡិន
- សេរី : (៤០១) ៩១៩-៩៩៥៤

**ទូរស័ព្ទវិទ្យុសម្លេងខ្មែរអាមេរិកាំង**
- ស៊ីជន : (២១៥) ២៨៤-១៣៨៣

Email : thekhmerpostEC@gmail.com

KHMER BILINGUAL BIWEEKLY NEWSPAPER

VOLUME 02 | ISSUE 17 | July 09th- 23th | 2008 | ADVERTISING (267) 253-3947 | WWW.THEKHMERPOST.COM

## តើតាម៉ុក បាននិយាយអ្វីខ្លះជាមួយ ពិន សំខុន នៅថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៩៨

ដោយ : ពិន សំខុន

•••កាលពីលេខមុនយើងបានលើកបទសម្ភាសន៍មួយជាមួយបងធំទី១ ប៉ុល ពត មកផ្សាយ ។ ស្ថានភាព (តទៅទំព័រទី២០)



## ក្រុងខ្មែរជួបវិបត្តិសេដ្ឋកិច្ចធ្លាក់ចុះ
*អ្នកជំនួញ និងប្រជាជនថ្ងូចថ្ងូរពីជីវភាព ព្រោះទំនិញឡើងថ្លៃ

***ឡុងប៊ិច : មាជ សុវណ្ណារ៉ា***

•••វិបត្តិសេដ្ឋកិច្ចសកលភាវូបនីយកម្មពិភពលោកមិនថាតែប្រទេសណាឡើយ ដូចជានៅសហរដ្ឋអាមេរិកនេះ កំពុងតែជួបនូវវិបត្តិសេដ្ឋកិច្ច និងបញ្ហានយោបាយ ដែលតែងតែមានការផ្លាស់ប្តូរជាបន្តបន្ទាប់ ។ បញ្ហាប្រេង និងទំនិញការលក់ដូរអចលនៈទ្រព្យធនាគារផ្អាកការខ្ចីប្រាក់លក់ ឬទិញផ្ទះជាដើម គឺជាផ្ទាំងស៊ីបក្នុងជីវភាពរស់នៅរបស់មនុស្សជាចាំបាច់ និងប្រចាំជីវិតជារៀងរាល់ថ្ងៃ ។ ជ្រុងមួយ ( តទៅទំព័រទី០៩ )

## អង្គការបំរើសេហគមន៍ខ្មែរ UCC អាចបិទទ្វារ?
*អ្នកដឹកនាំ UCC អំពាវនាវជាបន្ទាន់មួយស្វែងរកជំនួយថវិកាសង្គ្រោះកុំឱ្យដួលរលំ :

***ឡុងប៊ិច : មាជ សុវណ្ណារ៉ា*** នាយកប្រតិបត្តិអង្គការសហគមន៍ខ្មែរ (UCC) ដែលជាស្ត្រីមានវ័យជាង៤០ឆ្នាំ មកកាន់តំណែងនេះ ក្នុងរយៈពេល១៥ខែ អ្នកស្រី Sara Pol-Lim បានប្រាប់ខ្មែរប៉ុស្តិ៍នៅ ( តទៅទំព័រទី០៨ )



# វិស្សមកាលនៅវត្តព្រះពុទ្ធវង្ស៍



កុលបុត្រទើបចូលបួសកំពុងរៀនអក្សរខ្មែរ និងព្រះពុទ្ធសាសនា

ដោយ : ខ្មែរប៉ុស្តិ៍

•••នៅហ្វីឡាដែលហ្វីយ៉ានៃសហរដ្ឋអាមេរិក ដែលសម្បូរដោយអំពើហឹង្សាជាងគេ ។ វត្តព្រះ ពុទ្ធវង្ស៍ បានខិតខំបន្តកម្មវិធីបួសរៀននៅរដូវវិស្សមកាលជាថ្មីម្តងទៀត ។ ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៨ នេះ យុវជន២០នាក់ បានធ្វើការលះបង់ដ៏សំខាន់មួយ ដែលមានអាយុចាប់ពី៨ដល់២១ឆ្នាំ ពិធីបំបួសនាគបានចាប់ផ្តើម ហើយ នេន ទាំងដប់អង្គ បានថ្វាយខ្លួនបំរើឱវាទរបស់ព្រះពុទ្ធ ក្នុងរយៈពេល១ខែ ហើយមាន៥នាក់ទៀត ចូលបំរើព្រះធម៌តែមិនបានបួសទេ ។ (តទៅទំព័រទី១៨)

## សួស្តីបុណ្យកំណើតនៃសហរដ្ឋអាមេរិក
## HAPPY BIRTHDAY AMERICA

ដោយ : ពិន សំខុន

••• កាំជ្រួចបានបាញ់ឡើងទៅលើលំហរអាកាសយ៉ាងច្រើនសន្ធឹកសន្ធាប់ បែកពណ៌ជាផ្កាភ្លើពេញផ្ទៃមេឃនៃសហរដ្ឋអាមេរិក នារាត្រីទី៤ កក្កដា ២០០៨ ដើម្បីរំលឹកការប្រកាសឯករាជ្យជាដំបូងបង្អស់ នៅហ្វីឡាដែលហ្វីយ៉ា ជំនួសឱ្យរដ្ឋចំនួន ១៣ នាឆ្នាំ១៧៧៦ ពេលនោះសហរដ្ឋអាមេរិកលែងជាចក្រភពអង់គ្លេសតទៅទៀតហើយ ។ នៅហ្វីឡាដែលហ្វីយ៉ា ក៏ដូចជាទីក្រុងតូចធំឯទៀតៗ មនុស្សម្នាគ្រប់គេហដ្ឋាន គេជួបជុំគ្នានៅជុំវិញបរិវេណផ្ទះ ឬនៅសួនឧទ្យានធំ ដើម្បីជប់លៀងភោជនាហារ ឬភេសជ្ជៈ ឬស្តាប់ការ ប្រគំតន្ត្រី ឬនៅតាំងតែពីព្រឹក រហូតដល់អាធ្រាត (តទៅទំព័រទី០៧)

សូមអញ្ជើញស្តាប់វិទ្យុសម្លេងខ្មែរអាមេរិកកាំង
AM 1540 ផ្សាយចេញពីស្ថានីយ៍ New world Radio







វិទ្យុសម្លេងខ្មែរអាមេរិកកាំង

Youth Voice Project
Phone : Glenn Wrighten
267-918-6284

Every Saturday 3-4 PM

Voice of Khmer
Phone :
(215) 722-2226

# ទំព័រដកស្រង់ពីការអានសៀវភៅ

•••ថ្ងៃនេះ សុជាតា សេត បានអានសៀវភៅមួយ ដែលមានឈ្មោះថា "**Tuesdays with Morrie**" ដែលសេចក្ដីដកស្រង់មានដូចខាងក្រោមនេះ ។

**Tuesdays with Morrie: an old man, a young man, and life's greatest lesson** - Albom, Mitch

Mitch Albom was a musician. After suffering the loss of auncle,



សុជាតា សេត

an important figure in his life, and an unsuccessful job searching in the music business he switched his career to sports. He became successful professionally and financially in the sport broadcasting field. Back when he was in college, Mitch took a class of sociology with a prominent professor, Dr. Morrie Schwartz, who by his way of teaching and communicating had a positive impact on him and his academic work. They became close friends. But after his college graduation Mitch went on with his life pursuing a dream of becoming a famous pianist in New York City. For many years that followed he not only had no contact with his former professor, but life was such a way that made him think rarely of his beer-drinking friends at Brandeis University and the Tuesdays that he and Morrie used to meet to discuss on his thesis and talk about things such as "**being human**" and "**relating to others**". Absorbed by his busy and successful life, Mitch didn't know of his former teacher's health condition. Until one late night, while zapping his TV remote control, he learned by accident about Morrie's terminal illness. He then started to reconnect with his old professor. Traveling from Detroit Mitch agreed to visit him in West Newton, Massachusetts, every Tuesday. It's the Tuesday's meetings that gave birth to this little yet wonderful book on the subject of life. Every one should read this type of books at least once during one's life time, preferably before their 50th birthday. And especially those of us who are caught up in our societies that praise the material and social status success. This book treasures the greatest life's lessons that remind us not to forget "to live" and "let live". As Morrie said "Everyone knows they're going to die, but nobody believes it".

**Socheata Seth, Librarian**

PS: **Tuesdays with Morrie** is mandatory for some High Schools in Philadelphia as a summer reading book.

If you liked this book you may also like:

**The last lecture** - Randy Pausch and Jeffrey Zaslow

**The power of now : A guide to spiritual enlightenment** - Tolle, Eckhart

**A new earth : Awakening to your life's purpose** - Tolle, Eckhart

**Inspiration : your ultimate calling** - Dyer, Wayne W.

ខុមហ្វ្រែល COMFREL

**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)**

**COMMITTEE FOR FREE AND FAIR ELECTIONS IN CAMBODIA (COMFREL)**

ទីស្នាក់ការកណ្ដាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA. P.O. Box 1145, Tel: (855) 23 884 150 Fax: (855) 23 883 750 E-mail: comfrel@online.com.kh URL: www.comfrel.org

គណៈកម្មាធិការនាយក
BOARD OF DIRECTORS

លោក ធន សារាយ
Mr. THUN Saray
ជាប្រធានគណៈកម្មាធិការនាយក និងជាប្រធានសមាគម ADHOC

លោក សុក សំអឿន
Mr. SOK Sam Oeun
ជាអនុប្រធានគណៈកម្មាធិការនាយក និងជានាយក CDP

លោក យឹម ប៉ូ
Mr. YIM Po អគ្គលេខាធិការ និងជានាយក CCPCR

លោក យៀង វណ្ណា
Mr. YEANG Vanna
ប្រធាន KKKHRA

លោក ជីវ យូម៉េង
Mr. CHIV You Meng
ប្រធាន KYA

លោកស្រី ភឹង យក់ហៀប
Ms. PEUNG Yok Hiep
នាយិកា LAC

លោក យ៉ង់ គីមអេង
Mr. YONG Kim Eng
ប្រធាន PDP Center

លោក ទូច ទុម
Mr. TOUCH Tum
នាយក VIGILANCE

លោកស្រី ទីវ សារាយេត
Ms. TIV Sarayet
សហនាយិកា WMC

លោក មុំ សារិន
Mr. MOM Sarin
នាយក HRCDO

កញ្ញា សាយ សារ៉ា វឌ្ឍនី
Ms. SAY Sara Vathany
នាយិកា CWCC

លោក ភួង សិទ្ធិ
Mr. PHUONG Sith
តំណាងរដ្ឋ

លោក សេន សែត
Mr. SEN Set
តំណាងរដ្ឋ

ស.ប្រ.ក.៣/លេខ ០៩/០៨ គ.ប.ស.យ/អ.ក

## សេចក្ដីថ្លែងការណ៍

## ស្ដីពី

## បរិយាកាសឃោសនាបោះឆ្នោត ឆ្នាំ ២០០៨ រយៈពេលមួយសប្ដាហ៍ដំបូង

*រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០០៨*

គណៈកម្មាធិការ ខុមហ្វ្រែល សង្កេតឃើញថា បរិយាកាសសន្តិសុខជាទូទៅក្នុងដំណើរការឃោសនាបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៤ ក្នុងសប្ដាហ៍ទី ១ នេះ មានសភាពប្រសើរជាងបើប្រៀបធៀបទៅនឹងការបោះឆ្នោតឆ្នាំ២០០៣ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ករណីបំភិតបំភ័យ គំរាម-កំហែង រារាំង ពាក់ព័ន្ធនឹងគណបក្សនយោបាយ កំពុងកើតមានចំពោះអ្នកនយោបាយ និងសកម្មជនគណបក្សសំខាន់ៗ ជាបន្តបន្ទាប់យ៉ាងហោចណាស់ ១៦ ករណី។ ខុមហ្វ្រែល ថ្កោលទោសចំពោះអំពើហិង្សារបស់មន្ត្រីយោធា និងការប៉ុនប៉ងរបស់អាជ្ញាធរមូលដ្ឋានប្រឆាំងបេក្ខជនស្ត្រី លោកស្រី មូរ សុខហួរ ។ ខុមហ្វ្រែល អំពាវនាវឱ្យអ្នកនយោបាយ អ្នកគាំទ្រគណបក្សនិមួយៗ និងអាជ្ញាធរ កងកម្លាំងប្រដាប់អាវុធ សុំកុំប្រើអំពើហិង្សាក្នុងការដោះស្រាយបញ្ហា និងត្រូវចេះអត់ឱនឱ្យគ្នា រស់នៅក្នុងសហគមន៍ជាមួយគ្នា បើទោះបីមានមតិ និងសកម្មភាពនយោបាយខុសគ្នាក៏ដោយ" ។

លោក ធន សារាយ ប្រធានគណៈកម្មាធិការនាយក ខុមហ្វ្រែល បង្ហាញការចាប់អារម្មណ៍ថា *"ក្នុងកំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោតលើកនេះ មន្ត្រីរាជការ អាជ្ញាធរ និងកងកម្លាំងប្រដាប់អាវុធបានចូលរួមក្នុងសកម្មភាពគាំទ្រគណបក្សកាន់អំណាច ហើយក៏ធ្វើសកម្មភាពប្រឆាំងគណបក្សផ្សេងៗទៀតយ៉ាងច្រើនបើប្រៀបធៀបទៅនឹងការបោះឆ្នោតលើកមុន"* ។

ប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិច ទូរទស្សន៍ និងវិទ្យុឯកជនយ៉ាងហោច ៣០ ស្ថានីយដែលគាំទ្រគណបក្សប្រជាជនកម្ពុជាបានបន្តរំលោភនីតិវិធី បទបញ្ជា និងសេចក្ដីណែនាំរបស់គណៈកម្មាធិការជាតិរៀបចំការបោះ-ឆ្នោត (គ.ជ.ប) ទាក់ទិនគោលការណ៍ស្មើភាព និងសមធម៌ក្នុងការជួលម៉ោងដល់គណបក្សនយោបាយផ្សេងៗ ។

ខុមហ្វ្រែល មានការសោកស្ដាយយ៉ាងខ្លាំងដែលអ្នកបោះឆ្នោតមួយចំនួននឹងបាត់បង់សិទ្ធិបោះឆ្នោត ហើយក៏នឹងអាចធ្វើឱ្យមានការយល់ច្រឡំថា បាត់បង់សិទ្ធិបោះឆ្នោត ។ បញ្ហាទាំងនេះដោយសារមូលហេតុមួយក្នុងចំណោមមូលហេតុផ្សេងៗទៀតនោះគឺ ការរើសអើងនយោបាយ ក្នុងការសម្អាតបញ្ជីឈ្មោះ និងការបែងចែងប័ណ្ណព័ត៌មាន ដោយអាជ្ញាធរមូលដ្ឋានភូមិ ឃុំ/សង្កាត់ ។

ខុមហ្វ្រែល មានការព្រួយបារម្ភអំពីនីតិវិធី និងកំណត់ហេតុបូកសរុបលទ្ធផលបោះឆ្នោតគ្មានតម្លាភាព និងអនីត្យា-នុកូលភាព។ ព្រោះដំណើរការនីតិវិធីរបស់ គ.ជ.ប ណែនាំឱ្យធ្វើកំណត់ហេតុបូកសរុប ដោយគណៈកម្មការខេត្ត/ក្រុងរៀបចំការបោះឆ្នោត(គខ/កប)ដែលចេញពីកំណត់ហេតុបូកសរុបរបស់គណៈកម្មការឃុំ/សង្កាត់រៀបចំការបោះឆ្នោត (គឃ/សប) ផ្ទុយពីច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលចង្អុលបង្ហាញថា គខ/កប ត្រូវបូកសរុបលទ្ធផលបោះឆ្នោតចេញពីកំណត់ហេតុការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត។ លោក គល់ បញ្ញា បង្ហាញការព្រួយបារម្ភថា ***ការបាត់បង់សិទ្ធិអ្នកបោះឆ្នោត ឧបសគ្គផ្សេងៗដល់អ្នកបោះឆ្នោត រួមជាមួយអនីត្យានុកូលភាពនៃការបូកសរុបលទ្ធផលបោះឆ្នោត អាចនាំមកការប៉ះពាល់ដល់ដំណើរការ និង ទំនាស់លើលទ្ធផលបោះឆ្នោតនៅតាមមណ្ឌលខេត្ត/ក្រុង ។***

ខុមហ្វ្រែល គ្រោងបង្រៀន និងពង្រាយអ្នកសង្កេតការណ៍ប្រមាណ ១០.០០០ នាក់ ដើម្បីសង្កេតភាពមិនប្រក្រតី និងជួយអ្នកបោះឆ្នោតក្រៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត(ក្នុងទីតាំងការិយាល័យបោះឆ្នោតមួយមានអ្នក-សង្កេតការណ៍ខុមហ្វ្រែលម្នាក់ សរុបជាចំនួនច្រើនជាង ១០.០០០ ការិយាល័យដែលត្រូវសង្កេត) រហូតដល់ម៉ោង១១ ថ្ងៃត្រង់ ហើយបន្ទាប់មកពួកគេនឹងចូលសង្កេតក្នុងការិយាល័យវិញ។ ក្នុងនោះ ចំនួន ១.៣១៩ ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលចាប់ដោយចៃដន្យនឹងត្រូវបានអ្នកសង្កេតការណ៍របស់ ខុមហ្វ្រែល ប្រមូល និងបញ្ជូនរបាយការណ៍ភាពមិនប្រក្រតីធ្ងន់ធ្ងរនិងលទ្ធផលបោះឆ្នោតយ៉ាងលឿនមកទីស្នាក់ការកណ្ដាល ខុមហ្វ្រែល។ ក្នុងយុទ្ធនាការឃោសនាបោះឆ្នោត ខុមហ្វ្រែល បានកំពុងដាក់អ្នកសង្កេតការណ៍ ២១០ នាក់ ។

លោក ធន សារាយ និងលោក សុក សំអឿន អនុប្រធានគណៈកម្មាធិការនាយកខុមហ្វ្រែល រួមគ្នាអំពាវនាវ និងក្រើនរំលឹកដល់អ្នកពាក់ព័ន្ធការបោះឆ្នោត ( ប្រព័ន្ធផ្សព្វផ្សាយ គណបក្សនយោបាយ អាជ្ញាធរ...) ត្រូវគោរព និងអនុវត្តតាមច្បាប់ បទបញ្ជា នីតិវិធី និងសេចក្ដីណែនាំបោះឆ្នោតដើម្បីទប់ស្កាត់ទំនាស់ និងជម្រុញឱ្យការឃោសនាបោះឆ្នោត និងដំណើរការបោះឆ្នោត រាប់សន្លឹកឆ្នោតប្រព្រឹត្ត ទៅមានតម្លាភាព សេរី និងយុត្តិធម៌ ។ អ្នកដឹកនាំនយោបាយ គួរចៀសវាងកុំប្រើប្រាស់ពាក្យអសុរសនៅក្នុងអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោតនេះ ព្រោះអាចបង្កឱ្យមានអំពើហិង្សាកើតឡើងបានរវាងអ្នកគាំទ្រ និងសកម្មជនគណបក្សនិមួយៗ ។

*សូមទាក់ទងវាគ្មិន:*

- លោក **ធន សារាយ** ប្រធានគណៈកម្មាធិការនាយក ខុមហ្វ្រែល ទូរស័ព្ទ: ០១៦ ៨៨០ ៥០៩
- លោក **សុក សំអឿន** អនុប្រធានគណៈកម្មាធិការនាយក ខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៩០១ ១៩៩
- លោក **គល់ បញ្ញា** នាយកប្រតិបត្តិ ខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៩៤២ ០១៧

*បេសកកម្មទី ១ របស់ ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តធម៌ តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមរម្យ ការអប់រំដើម្បីផ្ដល់ព័ត៌មានដល់អ្នកបោះឆ្នោតអំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្ដល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃលើដំណើរការបោះឆ្នោតមួយ ដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ។*

## បាត់ដំបងឥឡូវ មានប្លែក...

លោក ក្រម រឿយ អាយុ៣៩ឆ្នាំ អ្នកនាំភ្ញៀវទេសចរខេត្តបាត់ដំបង បានឱ្យដឹងថា ចំពោះភ្ញៀវទេសចរអន្តរជាតិភាគច្រើនចូលចិត្តទៅកំសាន្តនៅភ្នំសំពៅ ប្រាសាទបាណន់ ពីព្រោះទីនោះមានរូងសត្វប្រចៀវ មានល្អាង និងធម្មជាតិស្រស់ត្រកាលប្លែកភ្នែកចំលែកអារម្មណ៍ ។

លោក ក្រម រឿយ បន្តថា ភ្ញៀវទេសចរខ្លះទៀតទៅមើលសារមន្ទីរភូមិវប្បធម៌ ផ្ទះបុរាណចំការក្រូច នៅស្រុកបាណន់ និងបរវេល ។ ចំណែកភ្ញៀវទេសចរខ្មែរមកពីខេត្តផ្សេងៗច្រើនទៅកំសាន្ត នៅសេកសក ចំលងគួយ ភ្នំសំពៅ ចំការផ្លែឈើដើរទិញអីវ៉ាន់នៅផ្សារណាត់ និងនៅតំបន់អូរដំបង ស្រុកសង្កែ នាំគ្នាជិះរទេះភ្លើង ឬស្សីយ៉ាងសប្បាយជក់ចិត្ត ។

*** ដំណើរកំសាន្តនៅពេលយប់ :**

បន្ទាប់ពីដើរកំសាន្តពេលថ្ងៃអស់ចិត្តហើយ នៅពេលយប់ភ្ញៀវមួយចំនួន ទៅលំហែកាយតាមដងស្ទឹងសង្កែខ្លះ ទៀតទៅទទួលទាននៅអាហារដ្ឋានកុលាប ដែលមានម្ហូបអាហារឆ្ងាញ់ និងតំលៃសមរម្យ និងមួយចំនួននៅរង្គសាលបុប្ផាទិព្វរាំកំសាន្តសប្បាយ ។

លោក ក្រម រឿយ បានឱ្យដឹងថា បាត់ដំបងសព្វថ្ងៃមានសណ្ឋាគារ ផ្ទះសំណាក់ អាហារដ្ឋាន ខារ៉ាអូខេ ស្រីបំរើផ្លូវភេទរីកដូចផ្សិតរង់ចាំបំរើភ្ញៀវគ្រប់ប្រភេទមិនឱ្យទាស់ចិត្តឡើយ ។ ប៉ុន្តែក្នុងនោះក៏មានកន្លែងខ្លះ ដូចជា រង្គសាលស្ដាយ៍ជាកន្លែងរាំច្រៀងរបស់ពួកយុវជនដែលញៀនថ្នាំឧស្សាហ៍ទៅទីនោះ ហើយភ្ញៀវដែលទៅទីនោះក៏ត្រូវតែប្រយ័ត្នប្រយែងទ្រព្យសម្បត្តិផងដែរ ។

លោក ក្រម រឿយ បញ្ជាក់ថា អ្នកដែលទៅដល់បាត់ដំបងភាគច្រើន គេនាំគ្នាភ្លក់អាហារឆ្ងាញ់មួយចំនួនដូចជា អាម៉ុក ប្រហុកខ្ទិះ ដូងខ្ចី និងក្រូចពោធិ៍សាត់ ដែលម្នាក់ៗ ពេលបានទទួលទានហើយលាន់មាត់សរសើរគ្រប់ៗគ្នា ។

*** តំបន់ទេសចរណ៍ :**

ខេត្តដ៏ចំណាស់នេះមិនត្រឹមតែសំបូរធនធានធម្មជាតិប៉ុណ្ណោះទេ ថែមទាំងមានតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រយ៉ាងច្រើន ដែលធ្វើឱ្យអ្នកទេសចរចង់ឃើញ លុះពេលបានទៅដល់ហើយអួតសរសើរមិនដាច់ពីមាត់ពីសម្រស់ធម្មជាតិនៅទីនោះ ។

ចំណែកឯនៅតាមបណ្ដាស្រុកនានា សំបូររមណីយដ្ឋានទេសចរណ៍ប្រវត្តិសាស្ត្រប្លែកៗទាក់ទាញភ្ញៀវទេសចរឱ្យទៅទស្សនាកាន់តែច្រើនដែរ ។ លោក ឃិន សុឃុន អាយុ៤២ឆ្នាំ រស់នៅភូមិអូរឃ្មុំ ឃុំស្ដៅ ស្រុករតនមណ្ឌល ដែលមន្ត្រីអង្គការពុទ្ធសាសនា ដើម្បីអភិវឌ្ឍន៍បានឱ្យដឹងថា រមណីយដ្ឋានធម្មជាតិដែលមានសម្រស់ធម្មជាតិល្អនោះ មានដូចជា សេកសក ពពុះ ពេជ្រចិន្តា ចំលងគួយ កោះស្នេហ៍ជ្រលងបុព្វតាល្អាងស្ពាន ភ្នំសំពៅ ភ្នំរំសាយសក់ ភ្នំក្ដោង ភ្នំតាគ្រាម ភ្នំអណ្ដើក ភ្នំទ្រុងមាន់ ភ្នំទ្រុងទា ភូមិអណ្ដែតទឹក បន្ទាយសត្វ និងល្អាងបុរាណជាច្រើនទៀត ទាក់ទិននឹងប្រវត្តិភូមិស្រុកនៅទីនោះ ។



ភ្ញៀវបរទេសកំពុងជិះអូតូរ៉ៃនៅខេត្តបាត់ដំបង



សួនយុវជនក្នុងខេត្តបាត់ដំបង



ផ្សារណាត់នៅទីប្រជុំជនខេត្តបាត់ដំបង

លោក ឃិន សុឃុន បន្តថា ក្រៅពីនេះ ខេត្តនៅមានវត្តបុរាណរមណីយដ្ឋានកែថ្ម អាងកំពីងពួយ ដែលកន្លែងពួក ប៉ុល ពត ធ្វើទារុណប្រជាជនឱ្យជីកដី ភ្នំតាហុក ដែលកំពុងតែជួយពង្រីកការងារឱ្យប្រជាពលរដ្ឋកាន់តែច្រើន ។ ដើម្បីឱ្យវិស័យទេសចរណ៍កាន់តែប្រសើរនោះ អាជ្ញាធរបានរៀបចំសណ្ឋាគារផ្ទះសំណាក់អាហារដ្ឋានសំរាប់បំរើវិស័យនេះ កាន់តែច្រើន ។

អ្នកស្រី វ៉ា សុខអ៊ឹម រស់នៅភ្នំពេញបានឱ្យដឹងថា ពេលគាត់មកបាត់ដំបងម្ដងៗមិនដែលភ្លេចទៅមើលភ្នំសំពៅនោះទេ ពីព្រោះវាមានខ្យល់អាកាសល្អ មានល្អាង ជាច្រើន និងមើលភូមិវប្បធម៌ដំណាំ ផ្លែឈើ និងភូមិវប្បធម៌ ផ្ទះបុរាណដែលបន្សល់ទុកតាំងពីសម័យបុរាណម្ល៉េះ ។

អ្នកស្រី វ៉ា សុខអ៊ឹម បន្តថា ពេលត្រឡប់ទៅក្រុងភ្នំពេញវិញ គាត់តែងតែឈប់នៅលើផ្លូវជាតិលេខ៥ ភូមិអន្លង់វិល ឃុំអន្លង់វិល ស្រុកសង្កែ ដើម្បីទិញណែម និងក្រូច ដែលមានរសជាតិឈ្ងុយឆ្ងាញ់យកទៅផ្ញើកូនទទួលទាន ។ អ្នកស្រីបញ្ជាក់ថា បាត់ដំបងតែមានធម្មជាតិល្អស្រស់ និងសំបូរអ្វីៗសព្វបែបយ៉ាង ដូចលោក ស៊ិន ស៊ីសាមុត រៀបរាប់មែន ។

*** សំណង់អគារចាស់ៗត្រូវផ្លាស់ប្ដូរ :**

បាត់ដំបង គឺជាខេត្តមួយដែលមានសក្ដានុពលសេដ្ឋកិច្ចខ្លាំងជាងបណ្ដាខេត្តនានា ហើយគេសង្កេតឃើញបុព្វបុរសយើងបានកសាងសំណង់ផ្ទះសំបែង និងអគារខ្ពស់តាំងពីសម័យអាណានិគមបារាំង និងសង្គមរាស្ត្រនិយម ។

លោក ស៊ិន ណារ៉េត ប្រជាពលរដ្ឋរស់នៅទីរួមខេត្តនេះបានឱ្យដឹងថា ផ្ទះរបស់ត្រកូល អភ័យវង្ស (បាត់ដំបងសម័យលោកម្ចាស់) ត្រូវគេយកធ្វើជាកន្លែងធ្វើការរដ្ឋ និងផ្ទះនៅភូមិវត្តគរ ឃុំវត្តគរ ត្រូវបានអាជ្ញាធររៀបចំជា "ភូមិវប្បធម៌" សំរាប់ទាក់ទាញភ្ញៀវទេសចរជិតឆ្ងាយ ។

លោក ស៊ិន ណារ៉េត បន្តថា ចំណែកឯសំណង់ធំនៅសម័យសង្គមរាស្ត្រនិយម ត្រូវបានអាជ្ញាធរឃុបឃិតជាមួយឈ្មួញផ្លាស់ប្ដូរទីតាំងជាបន្តបន្ទាប់ ធ្វើឱ្យបាត់ដំបងកេរដំណែលដូនតាស្ទើរអស់ ក្នុងនោះរួមមាន : រោងចក្រតម្បាញ, គុកធំ មណ្ឌលកីឡា មន្ទីរកសិកម្ម និងមន្ទីរអប់រំយុវជន និងកីឡា ជាដើម ។

*** ទីសក្ការៈស័ក្តិសិទ្ធ :**

( តទៅទំព័រទី១៧ )


# លោកមានសុខភាពរាល់ថ្ងៃ មិនប្រក្រតី សូមប្រើ RELIV

## សក្ខីកម្ម

ខ្ញុំមានជំងឺ Cancer ខួរក្បាល ហើយបានវះក្បាលពីរដង ខ្ញុំស្ថិតក្នុងការព្យាបាល Chemotheraphy ១៨ ខែ ....ពីរឆ្នាំក្រោយមកខ្ញុំមានគ្រោះថ្នាក់រថយន្តទៀត ។

ពេលបានជួប Relive មួយឆ្នាំក្រោយមកការឈឺចុកចាប់ក៏បាត់ទៅអស់ ខ្ញុំប្រែមានកម្លាំង ហើយអាចហាត់ប្រាណវិញបាន មិនតែប៉ុណ្ណោះចុះទម្ងន់ទៀតផង ។

Stephanis -Emmons (817) 847-5476




The Reliv scientists formulate the most recent nutrition research into products that scientifically advance, nutritionally complete, and is proven to restore the boby functions.

**របៀបប្រើ :** រៀងរាល់ព្រឹក ដូស RELIV មួយស្លាបព្រាវង្វាល់ពីកំប៉ុង A មួយស្លាបព្រាវង្វាល់ទៀត ពីកំប៉ុង B ដាក់ទៅក្នុងកែវមានទឹកធម្មតា ឬទឹកផ្លែ ឈើ កូរលាយគ្នា រួចពិសារព្រឹកម្ដង ល្ងាចម្ដងទទួលលទ្ធផលទាន់ចិត្ត

● ទូរស័ព្ទសំរាប់ដាវ (636) 537-9715

ដាវ ① RELIV CLASSIC : A
② RELIV INNERGIZE : B

កុំភ្លេចឱ្យលេខ Reliv Distributor :
(RNC.# 7070 438001)

● ទូរស័ព្ទ : (267) 253-3947 សំរាប់ហៅ
បើលោកចង់ចែកចាយជូនមិត្តភក្តិបងប្អូនបន្ត
ទៅទៀតជា Relive Distributor

RCN# 7070438001 www.reliv.com

នៅ VIRGINIA CALL VANNDY 1-703 415- 6257

Please Call : (267) 253-3947

# UCC អង្គការមួយបំរើ...

ក្នុងការិយាល័យថ្មី មិនឆ្ងាយពីអគារចាស់ដែលជាទ្រព្យសម្បត្តិរបស់ UCC ហៅថាផ្ទះខ្មែរនោះក្នុងអតីតកាល ដែលត្រូវគេរឹបអូស ព្រោះតែអាស្រូវការប្រើប្រាស់ថវិកាមិនប្រក្រតីបាននិយាយថា ក្នុងនាមថ្នាក់ដឹកនាំរបស់សហគមន៍ខ្មែរ (UCC) កំពុងតែអំពាវនាវជាបន្ទាន់ ចំពោះអ្នកនយោបាយមូលដ្ឋាន អ្នកជំនួញក្រុមហ៊ុនធំៗ អង្គការក្រៅរដ្ឋាភិបាល ដើម្បីស្វែងរកថវិកាទ្រទ្រង់ស្ថាប័នសង្គមមនុស្សធម៌ខ្មែរមួយនេះ ឱ្យបន្តបេសកកម្មរបស់ខ្លួនទៅមុខទៀត ដើម្បីជាតម្រូវការនៃពលរដ្ឋខ្មែរនៅតំបន់ក្រុងឡុងប៊ិចនូវសេវាកម្មសង្គមកិច្ចនានា ។

សហគមន៍ខ្មែរ UCC អាចប្រឈមមុខនឹងការបិទទ្វាររបស់ខ្លួននៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៨នេះ ប្រសិនបើស្ថាប័នមួយនេះ មិនបានបង់ប្រាក់ពន្ធទៅរដ្ឋាភិបាលសហព័ន្ធ (IRS) តាមការកំណត់ទេនោះ ។ ទឹកប្រាក់ចំនួន ៥៧,០០០ ដុល្លារអាមេរិក តម្រូវឱ្យ UCC បង់ពន្ធចូលរដ្ឋក្នុងរយៈកាល៥ឆ្នាំកន្លងមក ដែលសហគមន៍មួយនេះអាក់ខានបង់ពន្ធទៅឱ្យ RIS បន្តពីមេដឹកនាំមុនៗ ដែលជាការតម្រូវឱ្យអ្នកស្រី Sara ទទួលរងនូវថ្មបាក់ជាបន្តនោះ ។

អ្នកស្រី Sara Pol-Lim និយាយថា យើងចាំបាច់ត្រូវតែបង់ពន្ធជូនរដ្ឋ ដែលមិនអាចចៀសផុត ប៉ុន្តែអ្វីដែលយើងទាមទារចង់បានជាជំហានដំបូង គឺយើងនឹងស្នើសុំទៅក្រសួងពន្ធដារ IRS មេត្តាកុំយកការប្រាក់ពីប្រាក់ជំពាក់ពន្ធដាររដ្ឋនោះ បើរដ្ឋយកពន្ធទាំងដើមទាំងការជំពាក់នោះ វាជាឧបសគ្គសំរាប់អង្គការយើងដែលត្រូវតែបង្ខំចិត្តបិទទ្វារ ដោយសារគ្មានមូលនិធិគាំទ្របន្ត ។


អ្នកស្រី Sara Pol-Lim នាយិកាប្រតិបត្តិអង្គការ UCC (រូបថត ឯល ចាន់ថា )

អ្នកស្រី Sara និយាយបន្តថា បើមិននិយាយពីប្រាក់ការនោះ គឺយើងជំពាក់ប្រាក់ពន្ធរដ្ឋចំនួនតែ៣៧,០០០ដុល្លារតែប៉ុណ្ណោះ ដែលនេះធ្វើឱ្យយើងមានតុល្យភាពអាចបន្តបេសកកម្មបានជាបន្តទៅរកអន្តរកាលណាមួយទៀត ។

អ្នកស្រី Sara Pol-Lim ប្តេជ្ញាចំពោះមុខអ្នកកាសែតខ្មែរប៉ុស្តិ៍យើងថា "ខ្ញុំកំពុងប្រឈមមុខនឹងទទួលរងនូវថ្មបាក់ទៅនឹងបេសកកម្មមួយក្នុងការជួយសង្គ្រោះ UCC ដែលខ្ញុំកំពុងបានស្នើទៅអ្នកតំណាងរាស្ត្រ Lura Richard San ដែលគាត់បានសន្យានឹងជួយ ធ្វើកិច្ចការនេះ ជាមួយ IRS ។ ចំណែកលោក Don Knalbe នាយកតំបន់ស្រុកទី៤ នៃរដ្ឋ California ខាងត្បូង ក៏លោកសន្យានឹងជួយគាំទ្រថវិកា ដើម្បីឱ្យ UCC អាចមានដំណើរការទៅបាន ដោយចៀសវាងការបិទទ្វារនោះផងដែរ" ។

នាយកប្រតិបត្តិនៃសហគមន៍ខ្មែរ UCC, Pol Lim Sara បានបង្ហើបថា កាលពីថ្ងៃទី២៧ ខែមិថុនាកន្លងទៅនេះ យើងមានពិធីរ៉ៃអង្គាសប្រាក់មួយបំណងស្វែងរកការគាំទ្រនូវមូលនិធិ ដើម្បីដោះស្រាយបញ្ហានៅចំពោះមុខ ដែល UCC កំពុងតែប្រឈមមុខទៅរកការបិទទ្វារនោះ ។ មានអ្នកនយោបាយក្រុមហ៊ុនធំៗ និងអង្គការសង្គមស៊ីវិល គេបានចាប់អារម្មណ៍ ដើម្បីបំពេញតម្រូវការដល់បេសកកម្ម UCC បន្តទៀត ។ ប៉ុន្តែអ្វីដែលជាដំណោះស្រាយ គឺវាកើតមានឡើង នៅខែកក្កដានេះ ថាតើ UCC នឹងទៅជាយ៉ាងណា? ។



ទន្ទឹងនឹងស្ថានការណ៍ប្រឈមមុខចំពោះវិបត្តិបច្ចុប្បន្នក្តី ក៏អ្នកស្រីនៅតែគិតថា អង្គការមួយនេះ នៅតែខ្លាំងដដែល "ពួកយើងបានបំរើប្រជាជនប្រមាណ១០០០នាក់ក្នុងមួយខែ ក្នុងសេវាកម្មសង្គមកិច្ចសាធារណៈការមិនគិតកម្រៃចំពោះសហគមន៍ខ្មែរឡុងប៊ិច" ។

ក្រុមសមាជិកក្រុមប្រឹក្សាភិបាល UCC និយាយថា ការពាក់ព័ន្ធទៅលើពន្ធដារ (Tax) ព្រោះតែការចំណាយប្រាក់សំរាប់សន្តិសុខសង្គម និងសុខមាលភាព ដែលជាធម្មតា IRS នឹងមិនបិទទ្វារអង្គការ UCC ទេ បើគេអាចជួយទៅបាន ពួកគេអាចមើលឃើញសេចក្តីត្រូវការនៅក្នុងសហគមន៍ខ្មែរទៅហើយថា វាយ៉ាងដូចម្តេចនោះ ? ។

កាលបរិច្ឆេទពីពាភាគ៤នៅឆ្នាំ២០០៥ រហូតដល់ពាភាគ៤នៃឆ្នាំ២០០៦ បានបូកបន្ថែមច្រើនជាង៥០,០០០ដុល្លារ មុនពេលពិន័យ ហើយនឹងប្រាក់ពន្ធច្រើនជាង២៨,០០០ដុល្លារត្រូវបន្ថែមពីលើ ។ រហូតមកដល់ឥឡូវនេះ UCC បានបង់ប្រាក់បំណុលចំនួន២១,០០០ដុល្លារ តាំងពីដើមមកហើយ ។

យោងតាមសំដី Dok ដែលបានប្រាប់កាសែត Press Telegram បានឱ្យដឹងថា លោកបានព្យាយាមដើម្បីរក្សាអង្គការ UCC នេះឱ្យមានជីវិតរហូតដល់ចុងបញ្ចប់របស់គាត់ ។ លោក James Dok បានបន្តថា "ពួកយើងបានដឹង

(តទៅទំព័រទី២០)

Washington Wellness Care មន្ទីរថែរក្សាខ្លួនប្រាណ "វ៉ាស៊ីនតុន"
Medical & Rehab.
ដោយវិជ្ជាពេទ្យ និងការបង្ហាត់រាងកាយឱ្យដើរឡើងវិញ
Medical & Rehab.
500 Washington Ave., 1st Fl.
Philadelphia, Pa 19147
Phone: 215.551.6838. Fax: 215.551.6718
Dr. Scott C. Tran, D.C. Dr. Michael Barno, D.C. Dr. Zohar Stark, M.D.
We are specialized in treating:
- Auto Accident Injuries - Work Related Injuries - Slip & Fall Injuries
យើងមានជំនាញក្នុងការព្យាបាល :
☞ របួសដោយគ្រោះថ្នាក់រថយន្ត ☞ របួសដោយទាក់ទងនឹងកន្លែងធ្វើការ ☞ របួសដោយរអិល ឬដួល
We have staffs who speaks Vietnamese, Chinese, and Cambodian
For Cambodian and Vietnamese Speaking Staff, please call Ricky Son at 215.380.1350
For English Speaking Staff, please call 215.551.6838
យើងមានបុគ្គលិកដែលនិយាយភាសា វៀតណាម, ភាសាចិន , និងភាសាខ្មែរ
ទាក់ទងជាមួយបុគ្គលិកខ្មែរ និងវៀតណាម សូមទូរស័ព្ទទៅ រីគី សុន (215) 380-1350
ទាក់ទងទៅបុគ្គលិកនិយាយភាសាអង់គ្លេស សូមទូរស័ព្ទទៅ (215) 551-6838

## ក្រុមខ្មែរក្នុងវិបត្តិសេដ្ឋកិច្ច...

ដែលខ្មែរប៉ុស្តិ៍បានជួបប្រទះនៅក្នុងសហគមន៍ខ្មែរឡុងប៊ិច ទាំងប្រជាជនក៏ដូចអ្នកជំនួញ បាននាំគ្នាថ្ងូចថ្ងូរពីជីវភាពប្រចាំថ្ងៃក្នុងការរស់នៅទៅនឹងសេដ្ឋកិច្ចដែលកំពុងតែធ្លាក់ចុះជាមួយទំនិញសព្វសារពើកើងឡើងជាលំដាប់ក្នុងពីរឆ្នាំចុងក្រោយនេះ ។

បងស្រី ដារី អាយុជាង៥០ឆ្នាំ បានប្រាប់ខ្មែរ-ប៉ុស្តិ៍ថា គ្រួសារគាត់មានជីវភាពសមល្មម ដែលក្នុងបន្ទុកគ្រួសារមានកូន៤នាក់ ធំពេញវ័យត្រូវប្រើប្រាស់ឡានចំនួន៥គ្រឿង ដែលពី២ឆ្នាំ មុនក្នុងមួយអាទិត្យចំណាយចាក់សាំងត្រឹមតែ ២៥០ ដុល្លារប៉ុណ្ណោះ ប៉ុន្តែឥឡូវត្រូវចំណាយទៅលើប្រេងសាំងតែមួយមុខរហូតជាង៧០០ដុល្លារក្នុងមួយអាទិត្យ ដើម្បីចរាចរទៅធ្វើការ និងកូនទៅរៀនផងនោះ ។ ដែលនេះមិនទាន់គិតពីការចំណាយទៅលើការបង់ភ្លើង ទឹក ហ្គាស ផ្ទះលិខិតធានារ៉ាប់រង និងការចាយវាយផ្សេងៗ ដូចជា ម្ហូបអាហារប្រចាំថ្ងៃទៀតនោះ ។

បងស្រី ដារី បន្តថា ប្តីរបស់គាត់ដែលចូលនិវត្តន៍ពីការងារហើយនោះ ក្លាយជាអ្នកដឹកជញ្ជូនកូន និងប្រពន្ធ ដោយប្រើឡានតែមួយ-ពីរប៉ុណ្ណោះ ដោយឡាន៣គ្រឿងទៀតត្រូវបញ្ឈរទុកនៅផ្ទះព្រោះតែសាំងឡើងថ្លៃ ដើម្បីកាត់បន្ថយការចាយវាយដែលគ្មានតុល្យភាពចំណូលនោះ ។

បងប្រុស ស៊ីនួន កម្មកររោងចក្រសាច់កំប៉ុងរស់នៅឡុងប៊ិច បើកឡានទៅធ្វើការនៅក្រុងអ៊ីវ៉ាញ រដ្ឋ California និយាយថា ប្រាក់បៀវ-ត្សរ៍ ប្រចាំខែរបស់គាត់មិនបានឡើងកើត ដើម្បីឱ្យសមស្របទៅនឹងតំលៃប្រេងឡើងថ្លៃគុណជាពីរ និងទំនិញក៏ឡើងខ្ពស់ដែរនោះ ដែលធ្វើឱ្យចំណូលគាត់រស់យ៉ាងពិបាកក្នុងការចំណាយចេញទៅវិញលើការបង់អ្វីផ្សេងៗ ដោយគាត់បានត្អូញត្អែរថា ខ្លួនមួយផង ចុះបើមានប្រពន្ធកូនដូចសេដ្ឋកិច្ច សព្វថ្ងៃមិនវណ្ណកទៅហើយ ។

លោក វឌ្ឍារិទ្ធិ ហៅ Mike និយាយថា ពីមុនគាត់មិនដែលហូបបាយកកព្រឹកទេ មុនទៅធ្វើការងារគាត់តែងចូលភោជនីយដ្ឋាន ឬហាងគុយទាវដើម្បីស្រស់ស្រូបអាហារ ទើបទៅធ្វើការ ។ ប៉ុន្តែឥឡូវហូបបាយកកព្រឹក ឬបបរសនៅផ្ទះម្តងហើយ ដើម្បីសន្សំលុយបំពេញតម្រូវការចាក់សាំងជាយានជំនិះ និងសំរាប់ទិញម្ហូបអាហារ ។

ចំណែកអ្នកស្រី រស់ ស្រីរ័ត្ន និយាយថា ក្រុមគ្រួសារគាត់បានរិតបន្តឹងការចំណាយចាយវាយជាលក្ខណៈហ៊ុហារ ហើយក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ។ គាត់បានផ្អាកដើរលេងប្រចាំសប្តាហ៍រៀងរាល់ចុងអាទិត្យជាលក្ខណៈគ្រួសារទៅកាន់ភោជនីយដ្ឋាន កន្លែងរាំកំសាន្តចូលផ្សារទិញទំនិញ សម្លៀកបំពាក់ គ្រឿងសំអាងកាយាឱ្យមកនៅត្រឹមតែមួយខែម្តង ព្រោះមិនអាចទ្រាំទ្រពីថវិកាចំណូលទៅនឹងទំនិញឡើងថ្លៃគ្រប់សព្វនោះ ។

ប្រុសវ័យចំណាស់ម្នាក់សុំមិនបញ្ចេញឈ្មោះអះអាងថា បញ្ហាវិបត្តិសេដ្ឋកិច្ច ប្រាក់ខែមិនឡើងការចំណាយច្រើន ដែលជាការជួបបញ្ហាក្នុងជីវភាព ដែលគាត់មានគូដណ្តឹងនៅស្រុកខ្មែរ ដែលពីមុនធ្លាប់តែផ្ញើលុយឱ្យចាយជាប្រចាំខែ៣០០ ដុល្លារនោះ ឥឡូវក៏ត្រូវកាត់បន្ថយនៅត្រឹមតែ ១៥០ដុល្លារដែរ ទោះបីស្រីស្នេហ៍ជាគូដណ្តឹងនោះ ដែលគាត់កំពុងស្រឡាញ់ប៉ុនភ្នំព្រះសុម៉េរនៅឯតណ្ហាក៏ដោយ ក៏មិនអាចទ្រទ្រង់រួចជា

( តទៅទំព័រទី១៨ )


# ភោជនីយដ្ឋាន ណាម វ៉ាង (ភ្នំពេញ)
## Nam Vang Restaurant

571 Unit # 1 Adams Avenue. Philadelphia, Pa 19120
(inside Hong Kong Market)
**(215) 742-9488**
Open 7 days a week from 9 a.m. – 9 p.m.
**បើក 7 ថ្ងៃក្នុងមួយអាទិត្យពីម៉ោង 9 ព្រឹក ដល់ 9 ល្ងាច**

**១_មុខជំនាញខាងម្ហូបខ្មែរយ៉ាងចំណាន ដូចជា:**
- គុយទាវភ្នំពេញ
- សាច់គោច្រនួចអាំង
- មីកន្ដាំង តាមរបៀបខ្មែរ
- មីគ្រឿងក្នុង
- មីសរសៃធំ
- គុយទាវគ្រឿងក្នុង

**២_មុខជំនាញម្ហូបវៀតណាមល្បីឈ្មោះ ដូចជា:**
- នំបញ្ចុកទឹកត្រីពិសេស
- នំប៉័ងបាតេ ឬសាច់គោអាំង
- ខគោ នំប៉័ង ឬមី និងគុយទាវ
- បាយឆា . សាច់ជ្រូក.សាច់មាន់អាំង



រៀងរាល់ថ្ងៃលោកអ្នកអាចពិសាទឹកក្រឡុកគ្រប់រស់ជាតិផ្លែឈើ ដូចជា : ទុរេន ឬ អាវូកាដូ ហើយជាពិសេស មានទឹកអំពៅកិនស្រស់ៗ


## Buy something... Sell something...Announce something...advertise on the Khmer Post Classifieds!

### WANTED

Nail Technicians Are Needed

Please call 215 - 834 - 0559

For details.

**Your Advertisement**

**Is Here For**

**Less than $20 for two weeks!**

### Clip & Fax This Classified Coupon

Classified Advertising

Name your category: Sales, Services, Fund Raisers...etc.

Our rates: $5.00 for up to 20 words

15 cents each additional words

Send us your ad in one of the following ways:

1. by Fax to (215) 722-2226

2-by mail to the Khmer Post 5730 Rising Sun Avenue. Philadelphia, Pa 19120

3-By phone (267) 253-3947

Payments methods: cash or checks.

Name:__________Address: __________

City__________

State __________Zip__________

Phone: ______Fax__________

Your Advertisement Message:

______________________________

______________________________

______________________________

South Philadelphia Library, 1700 S. Broad St.

**ESL classes,** Tuesdays & Thursdays 12:30-3:00 p.m.

**Books and DVDs in Khmer language**

South Philadelphia Branch, 1700 S .Broad St.

Whitman Branch, 200 Snyder Ave.

Greater Olney Branch, 5501 N. 5th St.

Wyoming Branch, 231 E. Wyoming Ave.


### Service

C.C. Building Services

Metropolitan Area



C.C. BUILDING SERVICES
*COMMERCIAL & RESIDENTIAL CLEANING*

CHEA CHHAY
*PRESIDENT*

50 NUGENT DRIVE
STAFFORD, VIRGINIA 22554
PHONE: (540) 720-4696
FAX: (540) 720-4697
CELL: (703) 606-9010

# Book review

## ដកស្រង់ការអានសៀវភៅរបស់លោក ស៊ីវ ស៊ីចាន់ ឈ្មោះ "ឆ្អឹងមាស"

Book review: Golden Bones: an Extrodinary Journey from Hell in Cambodia to a New Life in America by Sichan Siv. Reviewed by Lindsay Doering.

June 4, 2008 marks the 32nd anniversary of Ambassador Sichan Siv's arrival in the U.S. from Cambodia. In the Preface to his book Golden Bones, (also dated June 4, 2008), he writes that revisiting the past has caused him sadness and that his book is a "human story". Mr. Siv has shown great courage in writing such a candid and personal book. And, despite the fact that his life was tragically altered by a violent regime and despite his remarkable career in politics and international relations, his book is, at its heart, a human story. In telling the story, he honors the people he knew in Cambodia and describes the beauty of his new life in the U.S.



ស៊ីវ ស៊ីចាន់ ឈ្មោះ "ឆ្អឹងមាស"

The first half of the book takes place in Cambodia. Through numerous stories and anecdotes we learn about Mr. Siv's family, childhood and life in general in the 1960's and early 1970's. We learn how Mr. Siv completed his education and rose to a position of trust and responsibility within various international aid groups. These two accomplishments would, ironically, make him a target under the new regime. Mr. Siv was offered a seat on a plane to the U.S. when it was clear that his life would be in jeopardy if he stayed in Cambodia. In a dramatic turn of events, he missed the flight because of his commitment to his family and the humanitarian relief effort.

His ultimate escape from Cambodia involved many acts of courage in the face of almost constant danger. Yet Mr. Siv seems to think of himself as lucky rather than heroic. He was forced to rely on help from several strangers he encountered on his journey; and when he retraced his escape route years later, he tried to locate and thank these people. One gets the impression that his positive attitude, smile, and ability to connect with people were essential to his survival. These skills would also serve him well in the U.S.

Mr. Siv had managed to make contact with some Americans prior to coming to the U.S. who offered him a place to stay while he looked for a job. After brief, humorous stints as a restaurant trainee and a New York cab driver, he entered graduate school at Columbia University. It was also in New York that he met his future wife, a Texan by the name of Martha Pattillo. Having become acclimated to life in his new country, Mr. Siv set off on another journey ultimately leading to positions at the White House and the United Nations.

Mr. Siv's writing is unaffected, careful and entertaining. When he writes about his life in the U.S., he writes about everything he sees, from the trivial to the important. He writes about the intricacies of getting an appointment as an ambassador to the United Nations; and he writes about who holds the record for the fastest time eating a 72 ounce steak at a restaurant in Amarillo, Texas. Mr. Siv tells about setting up a meeting between His Holiness the Dalai Lama and President George Bush (41) and the fact that one of the President's dogs, "Ranger", was especially drawn to His Holiness. Mr. Siv finds joy everywhere. As he says in the final sentence of the book "This is a beautiful country".

However, this book is not really about America; it is a human story. It is about a faithful Buddhist, an American By Choice, a man who knows that "if you are in the mouth of a tiger, play with its teeth" and many other things. Mr. Siv has a particular fascination with historical dates; therefore it seemed appropriate that I read the book cover-to-cover on July 4, 2008. I believe that no other American has a greater appreciation of freedom than Ambassador Sichan Siv.

# លិនស៊ីដីង រាយការណ៍ពីរឿង កាស៊ីណូ

នៅផែនស៊ីវេនីញ៉ា ការបង្កើតកាស៊ីណូ ត្រូវបានអនុញ្ញាតិតាមផ្លូវច្បាប់រួចហើយ ក៏ប៉ុន្តែក្រុមអ្នកធ្វើច្បាប់បានចងជាសម្ព័ន្ធមួយប្រឆាំងនឹងវត្តមានកាស៊ីណូ ដែលនឹងត្រូវសាងសង់នៅខែកក្កដានេះ នៅមាត់ស្ទឹងដែលវែរ ។

ប៉ុន្តែការប្រឆាំងនេះ បានត្រឹមតែទាមទារឱ្យប្តូរទីកន្លែងសាងសង់តែប៉ុណ្ណោះ ។

Pennsylvania Legislators Form Alliance Against Current Philadelphia Casino Locations.

Be Lindsay Doering.


លោក លិនស៊ីដីង

In yet another stunning turn of events con - cerning the casinos slated to be built along the Delaware riverfront, on Thursday July 3rd, several key state legislators announced an alliance to say to the casino owners: "find a new location". The alliance includes State Senator Vince Fumo, one of the authors of the original casino legislation, Rep. Dwight Evans, as well other area representatives. Under the law, as it stands, the casinos must voluntarily relocate. However, should the casinos fail to voluntarily relocate, the legislators may attempt to repeal valuable tax breaks or pursue other tactics. A stated by Sen. Fumo: "we started making spit balls. This time, they'll be atom bombs."

In the last several weeks, Mayor Nutter has called for "honest, legitimate, third party analysis" of the casino locations. These statements conform to the widely held belief that no such studies have been done on the current sites. Casinos are loath to have such studies performed. There is an increasing body of data that indicates when gambling's adverse impact on crime, local business, government corruption, the number of bankruptcies and family life are factored in, gambling results in a net financial loss to many municipalities. Philadelphia, which already has problems in all of these areas, would be particularly vulnerable to the adverse effects of gambling.

This effort by Sen. Fumo and Rep. Evans is not "anti-casino" - the effort is limited to forcing the casinos to find a new location. Fair enough. Hopefully, however, their efforts will result in an objective analysis of the real impact casinos so that the people of the city can have the proper facts before them.

# ទាចាយុវជ័យ

កុមារ ឈីវ ហ៊ុងអេង អាយុ ៩ឆ្នាំ នៅហ្វីឡាដែលហ្វីយ៉ា ខាងជើងចង់សំដែងសេចក្តីរំភើបរបស់នាង នៅពេលបានធ្វើដំណើរទៅមាតុប្រទេសកម្ពុជារបស់ខ្លួនវិញជាលើកដំបូង ... នៅលើទំព័រ ខ្មែរ-ប៉ុស្តិ៍ ។

A Trip to My Homeland : By Chhivhung Eng, age 9

I was excited about visiting my homeland, Cambodia. I woke up really early to catch the plane. The air plane stopped many times. The air plane terminal was enormous. There were so many technologies. When I arrived in Cambodia, it was almost night time. I ate porridge when I got to my house. I was so happy to see my family. I was glad to see my dad, aunts, grandmothers, and uncle. They were happy to see me, too. Everyday, I ate breakfast at the market where my aunt sells clothes. I even got some backpack from my dad, because my dad sells the animals' stuff and the backpack. Everyone in my family gave me money on the day I left. The food was awesome. I gain about 2.5 pounds while I was Cambodia. It's relaxing in Cambodia. I didn't want to come back, but I have to. It was fun at Cambodia, and I can't wait until the next time I visit Cambodia again.


កុមារ ឈីវ ហ៊ុងអេង

# ការរិះគន់ជុំវិញការប៉ុនប៉ងដកអភ័យឯកសិទ្ធិសភាពី សម រង្ស៊ី

***ឡុងប៊ិច : សុភាបុត្រ***

●●●ក្នុងបណ្តឹងបរិហារកេរ្តិ៍ និងផ្សាយព័ត៌មានមិនពិតរវាងលោក ហោ ណាំហុង ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ តុលាការក្រុងភ្នំពេញបានធ្វើការស្នើសុំទៅរដ្ឋសភាឱ្យដកអភ័យឯកសិទ្ធិសភាពីលោក សម រង្ស៊ី ប្រធានគណបក្សប្រឆាំងដើម្បីបើកការស៊ើបអង្កេត ។

ចំណាត់ការដ៏តក់ប្រហល់របស់តុលាការក្រុងភ្នំពេញ ដែលមហាជនមើលឃើញថា មានលក្ខណៈលំអៀងទៅគណបក្សកាន់អំណាច ហើយចង់ដកអភ័យឯកសិទ្ធិសភាពីលោក សម រង្ស៊ី នេះ ធ្វើឱ្យមានប្រតិកម្មពីគណបក្ស សម រង្ស៊ី មន្ត្រីអង្គការសង្គមស៊ីវិល និងអ្នកច្បាប់យ៉ាងខ្លាំង ។

ការស្នើសុំដកអភ័យឯកសិទ្ធិសភាពីលោក សម រង្ស៊ី នេះ ក៏បានបង្ហាញឱ្យឃើញថា តុលាការក្រុងភ្នំពេញធ្វើការមានភាពលំអៀងមិនយកច្បាប់ជាគោល ដូចករណីបទបរិហាកេរ្តិ៍តាមរដ្ឋធម្មនុញ្ញពុំត្រូវជាប់ទោសដាក់គុកនោះទេ គឺគ្រាន់តែពិន័យជាប្រាក់តែប៉ុណ្ណោះ ។

ក្នុងលិខិតមួយច្បាប់ចុះថ្ងៃទី១៧ ខែមិថុនា ដោយលោក អ៊ុក សារុធ អគ្គព្រះរាជអាជ្ញាក្រុងភ្នំពេញ និងលោក ឯក ចេងហួត ព្រះរាជអាជ្ញារងបានផ្ញើលិខិតទៅលោក ហេង សំរិន ប្រធានរដ្ឋសភាកម្ពុជា ដើម្បីស្នើឱ្យដកអភ័យឯកសិទ្ធិសភាពលោក សម រង្ស៊ី ងាយស្រួលក្នុងការស៊ើបអង្កេត។ ការស្នើដោយតុលាការក្រុងភ្នំពេញបែបនេះ ដោយសារលោក សម រង្ស៊ី បាននិយាយបរិហារកេរ្តិ៍លោក ហោ ណាំហុង ថាជាអតីតប្រធានគុកបឹងត្របែកក្នុងសម័យខ្មែរក្រហម នៅឯវាលពិឃាតពីការភ័យស្លន់ស្លោរបស់គណបក្សប្រជាជនកម្ពុជា ខ្លាចចាញ់គណបក្ស សម រង្ស៊ី ពេលបោះឆ្នោតនៅថ្ងៃទី២៧ ខែកក្កដា ខាងមុខ ។

លោក សម រង្ស៊ី បានបញ្ជាក់ថា ទោះបីជាមានការគំរាមកំហែងបែបនេះក្តី ក៏ខ្ញុំនៅតែបន្តការងារជួបជាមួយម្ចាស់ឆ្នោតតាមមូលដ្ឋាន រហូតដល់ថ្ងៃបោះឆ្នោត និងគ្មានផែនការចាកចេញក្រៅប្រទេសគេចខ្លួននោះទេ ។



លោក សម រង្ស៊ី

ការប៉ុនប៉ងដកអភ័យឯកសិទ្ធិសភាពីលោក សម រង្ស៊ី នេះ បានធ្វើឱ្យមានប្រតិកម្មពីក្រុមអ្នកច្បាប់ និងអង្គការសង្គមស៊ីវិលថា បានធ្វើឱ្យបរិយាកាសនៅពេលបោះឆ្នោតកាន់តែអាប់អួរ និងស្នើឱ្យអ្នកនយោបាយបញ្ឈប់ការប្តឹងប្តល់រឿងបរិហារកេរ្តិ៍នេះ ។

សំរាប់អ្នកច្បាប់បានលើក ឡើងថាករណីបទបរិហារកេរ្តិ៍ នេះ គឺមិនមានទោសត្រូវជាប់ពន្ធនាគារនោះទេ ដោយគ្រាន់តែតំរូវឱ្យបង់ប្រាក់



លោក សុខ ផេង អតីតតំណាងរាស្ត្រគណបក្ស សម រង្ស៊ី



លោក សុខ សម្បត្តិ ចៅសង្កាត់គីឡូម៉ែត្រលេខ៦

បឹងជើងឯក កាលពី ថ្ងៃទី១៧ មេសា ជាយក្រុងភ្នំពេញ ។

ការស្នើឡើងយ៉ាងតក់ក្រហល់របស់តុលាការក្រុងភ្នំពេញ ដើម្បីដកអភ័យឯកសិទ្ធិសភាពីលោក សម រង្ស៊ី នេះ ទំនងជាមិនអាចទៅរួចពីព្រោះចំពេលដែលសភាសំរាក ដើម្បីចុះទៅឃោសនាបោះឆ្នោតតាមខេត្ត-ក្រុង ។

លោក ហេង សំរិន ប្រធានរដ្ឋសភាបានមានប្រសាសន៍ថា ករណីសុំព្យួរអភ័យឯកសិទ្ធិសភានេះ មានករណីច្រើនដែលសភាមិនអាចកោះប្រជុំបានទេ គឺលុះត្រាតែមានការស្នើពីព្រះមហាក្សត្រ ឬនាយករដ្ឋមន្ត្រីស្នើព្យួរអភ័យឯកសិទ្ធិទើបអាចធ្វើបាន ។

ចំណែកលោក សម រង្ស៊ី មេដឹកនាំគណបក្សសម រង្ស៊ី ក៏បានបញ្ចេញប្រតិកម្មជុំវិញការស្នើសុំរបស់តុលាការក្រុងភ្នំពេញ ដែលចង់ឱ្យសភាព្យួរអភ័យឯកសិទ្ធិរបស់លោកថា ការដែលពួកគេចង់ធ្វើបាបខ្ញុំ ចាប់ខ្ញុំនេះ គឺខ្ញុំគ្មានការបារម្ភនោះទេ ប៉ុន្តែផ្ទុយទៅវិញ ក៏បានបង្ហាញឱ្យឃើញ១០លានរៀល និងជំងឺចិត្តរបស់ជនរងគ្រោះនោះតែប៉ុណ្ណោះ ។ ចំណែកអ្នកគាំទ្រគណបក្ស សម រង្ស៊ី ក៏បានសំដែងនូវការព្រួយបារម្ភចំពោះករណីនេះ ខ្លាចក្រែងតុលាការបំពានច្បាប់ ចាប់ខ្លួនដូចលោក ដាំ សិទ្ធិ និពន្ធនាយកកាសែតមនសិការ ដែលជាប់ចោទពីបទបរិហារកេរ្តិ៍ និងផ្សាយព័ត៌មានមិនពិត ។

ជាមួយគ្នានេះដែរ លោក ប៊ុន រិទ្ធី ប្រធានអង្គការស្រាវជ្រាវជាតិកម្ពុជាបានប្រាប់អ្នកកាសែតថា ការពិតទៅការរិះគន់ជាសាធារណៈក្តីអសាធារណៈក្តី ឬព័ត៌មានបានចុះផ្សាយ បើម្ចាស់គេពិនិត្យទៅឃើញថា មិនពិត គេស្នើទៅអ្នកនោះឱ្យបំភ្លឺឡើងវិញ ។ ករណីនេះបើមិនបំភ្លឺទេ គេប្តឹងទៅតុលាការ ហើយបើរកឃើញថា មានទោសត្រូវពិន័យជាប្រាក់តាមច្បាប់ ។

លោក ប៊ុន រិទ្ធី បញ្ជាក់ថា ព្រះរាជអាជ្ញាតុលាការមិនអាចចាប់ចង ឬដាក់ពន្ធនាគារនោះទេ ។ ក្នុងមាត្រានៃច្បាប់ធម្មនុញ្ញទី២០, ២១ បានបញ្ជាក់ថា បទបរិហារកេរ្តិ៍គ្មានទោសគុកទេ

( តទៅទំព័រទី២០ )

## នេះជាបារមីនៃការលះ...

ប្រតិកម្មរបស់រដ្ឋាភិបាលខ្មែរបងប្អូនរួមឈាមយើង ពិសេសលោក ជ័យ មង្គល ច្បាស់ជារង់ចាំការឆ្លើយតបនៃយើងទាំងអស់គ្នា ដែលមានឈាមជាខ្មែរកំពុងហូរក្នុងសរសៃជាខ្មែរនេះមិនខាន ។ ការឆ្លើយតបនេះអាចជាលុយកាក់ប្រាក់កាសសម្ភារៈ ឬ ការពង្រឹងស្មារតីលើកទឹកចិត្ត ។ល។ ឬបង្ហាញពីគោលការច្បាប់អន្តរជាតិព្រមានដល់រដ្ឋាភិបាលក្រុងបាងកកឱ្យយកចិត្តទុកដាក់ពីបញ្ហានេះឱ្យមែនទែន ។ យើងក៏កុំភ្លេចទទូចសុំដល់រដ្ឋាភិបាលនៃប្រទេសកម្ពុជាមេត្តា ធ្វើអន្តរាគមន៍ដល់បុព្វហេតុរបស់បងប្អូនរួមលោហិតរបស់យើង ដែលត្រូវឃ្លាតពីរង្វង់ដៃនៃមាតុភូមិខ្លួនដ៏សែនយូរលង់... នេះជាឱកាសល្អ ដើម្បីឱ្យបងប្អូនយើងបានបង្ហាញនូវទឹកចិត្តអាណិតស្រឡាញ់គ្នា ឬក៏យើងភ្លេចអស់ទៅហើយ...? ឱកាសសំរាប់ជួយ ឬចូលរួមសាងអំពើកុសលមួយដ៏ធំមហិមាក្នុងនាមជាខ្មែរម្នាក់ដែលយើងមិនត្រូវមើលរំលងនោះ គឺសម្រែកដង្ហោយហៅរបស់បងប្អូនខ្មែរកម្ពុជាក្រោមយើង ដែលត្រូវជនជនជាតិដទៃរំលោភយកទឹកដី ហើយជិះជាន់ជាហូរហែរាប់សិបសតវត្សកន្លងមក ។ ឥឡូវនេះអង្គការសហប្រជាជាតិបានទទួលស្គាល់ ហើយប្រកាសឱ្យជនជាតិដើមអាចខំឈរឡើង ដើម្បីធ្វើម្ចាស់ចាត់ចែងវាសនាខ្លួនឯងដោយផ្ទាល់ និងក្រោមការឧបត្ថម្ភពីអន្តរជាតិ ។ នេះជាសិទ្ធិដែលបងប្អូនយើងត្រូវបាត់បង់អស់គ្មានសល់រាប់រយឆ្នាំមកហើយ ដោយជនជាតិដទៃឆ្លៀតឱកាសអ្នកដឹកនាំយើងបែកបាក់គ្នាក៏ចូលមកឆក់ប្លន់យកអំណាចធ្វើជាម្ចាស់ជិះជាន់អ្នកម្ចាស់ស្រុកទុកជាទាសករ ។ អង្គការសហប្រជាជាតិបានប្រកាសសិទ្ធិនេះ ឡើងមិនមែនជារឿងចៃដន្យនោះទេ តែការប្រឹងប្រែងយ៉ាងស្វិតស្វាញ និងយូរលង់នៃជនជាតិជាង៦០សញ្ជាតិលើពិភពលោក ដែលគ្មានរដ្ឋាភិបាល ហើយរស់ក្រោមការដឹកនាំរបស់រដ្ឋាភិបាលសាសន៍ដទៃនៅលើទឹកដីរបស់ខ្លួនទៅវិញ ។ នៅក្នុងចំណោមជនជាតិជាង៦០ ដែលខំប្រឹងតស៊ូដើម្បីរំដោះជាតិខ្លួនឱ្យផុតពីការជិះជាន់នោះ មានប្រជាជនប្រមាណជិត១០លាននាក់កំពុងទទួលផលពីការតស៊ូមតិលើឆាកអន្តរជាតិនោះដែរ គឺជាការតស៊ូអហិង្សាស្របនឹងគតិច្បាប់សម័យបច្ចុប្បន្ននេះ ។ នោះ ជាជនជាតិខ្មែរនេះឯង តែដោយលក្ខណៈភូមិសាស្ត្រ ដោយត្រូវជាតិសាសន៍ដទៃត្រួតត្រាជិះជាន់ច្រើនសតវត្សមកក៏សំនៀងនិយាយស្តីការរស់នៅមានភាពខុសប្លែកបន្តិចបន្តួចពីបងប្អូនអ្នកស្រុកខ្មែរ ។ ហើយដើម្បីសំគាល់ជនជាតិខ្មែរទាំងនេះ សម្តេចនរោត្តម សីហនុ បានដាក់ឈ្មោះថា ខ្មែរកម្ពុជាក្រោម ឬខ្មែរកូសាំងស៊ីន ។ គឺជាខ្មែរដែលមានដើមកំណើតជាអ្នកសាងអង្គរមានការឈឺចាប់វាយខ្មាំងសត្រូវការពារបូរណភាពទឹកដីអង្គរមរតកដូនតានៃយើងទាំងអស់គ្នា ។ តែបងប្អូនយើងអភ័ព្វត្រូវជនជាតិដទៃជិះជាន់ ។ ឥឡូវនេះបានសហព័ន្ធខ្មែរកម្ពុជាក្រោមដឹកនាំដោយបងប្អូនរួមឈាមយើង និងសង្ឃឹមបានរស់នៅក្នុងសន្តិភាពចាត់ចែងវាសនាខ្លួនដោយខ្លួនឯង ។ តែដើម្បីទៅដល់គោលដៅនោះ សហព័ន្ធខ្មែរកម្ពុជាក្រោមត្រូវការគាំទ្រពីមនុស្សជាតិដែលស្រឡាញ់សន្តិភាព និងយុត្តិធម៌ទាំងអស់លើពិភពលោក ពិសេសពីខ្មែរ គ្រប់រូបគ្រប់ជាន់ថ្នាក់ដោយការចូលរួមតស៊ូរួមជាយោបល់ផ្តល់មតិជាធនធានទ្រព្យសម្បត្តិជាដើម ។

ប្អូនត្រូវគេវាយគេចាប់ចងបងឈឺកន្លងស្ងៀមម្តេចបានបងប្អូនរួមផ្ទៃគេឈ្លានពានបងសុំព្រមាននឹងមរណា ។

ប្រសិនបើបងប្អូនមិនបានចូលរួមជាមួយគ្រូ អឹងថៃហ្វូ ឱកាសចូលរួមនៅមានច្រើនណាស់ ពិសេសឱកាសជួយស្រោចស្រង់អក្សរសាស្ត្រជាតិ ឬស្រោចស្រង់ទឹកដីជាឱកាសកម្របានជួបប្រទះ ។ សូមបងប្អូនរួមឈាមកុំបណ្តោយឱ្យឱកាសកន្លងផុតទៅ ដោយអត់បានចូលរួមឱ្យសោះ ។ ជនជាតិខ្មែរពិតជាមានមេ្យតមិនចាញ់ជាតិជិតខាងឡើយ ! ៕




Get Connect...Stay inform.

....Subscribe to the Khmer Post!

Please send me 1 year subscription of the Khmer Post newspaper 24 issues for $60.00

Name: ____________________

Address: ____________________

____________________

Payment method:

Money order Check Bill me

Please send your payment to US-Asia Media Group.
5730 Rising Sun Ave. Philadelphia, Pa 19120

# ចំណងប្រាំប្រការរបស់គណបក្សប្រជាជនកម្ពុជាក្នុងឥទ្ធិពលនយោបាយ

***ភ្នំពេញ : ចាន់ កុសល***

ចាប់តាំងពីសន្និសីទទីក្រុងប៉ារីស ប្រទេសបារាំងថ្ងៃទី២៣ តុលា ឆ្នាំ១៩៩១មក កម្ពុជាបានរៀបចំធ្វើការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ដែលមានការចូលរួមពីសហគមន៍អន្តរជាតិ ៣លើកហើយ ។ ប្រជាពលរដ្ឋខ្មែរគ្រប់ស្រទាប់វណ្ណៈបានបំពេញកាតព្វកិច្ចយ៉ាងល្អ គឺទៅបោះឆ្នោតជ្រើសរើសមេដឹកនាំថ្មី សំរាប់ធ្វើការដឹកនាំប្រទេសជាតិ អភិវឌ្ឍន៍សង្គម ស្របតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

បំណងប្រាថ្នារបស់ប្រជាពលរដ្ឋតាមរយៈការបោះឆ្នោត ដើម្បីជ្រើសរើសតំណាងរបស់ខ្លួនហាក់ដូចជាពុំទាន់ឆ្លើយតបតាមការចង់បានរបស់ពួកគាត់ឡើយ គឺជាប់តែកំអែលកុម្មុយនីស្តប៉ុន្មាននាក់នៅបន្តដឹកនាំដដែលៗ ។ ការដែលមេដឹកនាំកុម្មុយនីស្តនៅតែបន្តដឹកនាំបែបនេះ ត្រូវបានមតិជាតិ និងអន្តរជាតិរកឃើញថា បណ្តាលមកពីគណបក្សប្រជាជនកម្ពុជា ដែលក្តោបអំណាចតាំងពីឆ្នាំ១៩៧៩មកនោះ គ្រប់គ្រងលើប្រព័ន្ធ


លោក ទីម អ៊ីម អាយុ ៦៥ ឆ្នាំ


សកម្មជនគណបក្សប្រជាជនកំពុងជួបជុំគ្នា

ផ្សព្វផ្សាយមន្ត្រីយោធា ប៉ូលិស តុលាការ ការិយាល័យធិបតេយ្យស៊ីវិល និងមន្ត្រីមូលដ្ឋាន ។

តាមការសង្កេតជាទូទៅមន្ត្រីរាជការគ្រប់ផ្នែក តាំងពីថ្នាក់មូលដ្ឋានដល់ថ្នាក់កំពូល បានប្រើប្រាស់តួនាទី និងអំណាចរបស់ខ្លួនគ្របដណ្តប់ទៅលើកូនចៅមិនឱ្យបញ្ចេញមតិក្នុងរឿងនយោបាយ ។ ជាពិសេសនោះ បុគ្គលិកនៅតាមអង្គភាពនានាត្រូវតែក្លាយខ្លួនជាសមាជិកគណបក្សប្រជាជនកម្ពុជា បើពុំនោះទេ គឺពុំបានសេចក្តីសុខឡើយ ។ ចំណែកឯប្រជាពលរដ្ឋនៅតាមភូមិស្រុកក៏ត្រូវគេពង្វក់ បំភិតបំភ័យ និងចែកអំណោយបន្តិចបន្តួចឱ្យដើម្បីទៅបោះឆ្នោតឱ្យគណបក្សប្រជាជនកម្ពុជា ។

ប្រជាពលរដ្ឋភាគច្រើនបានធ្វើការត្អូញត្អែរថា កាលពីបោះឆ្នោតនៅឆ្នាំ១៩៩៣ ដែលរៀបចំដោយអង្គការសហប្រជាជាតិ ពួកគាត់បានធ្វើការបោះឆ្នោតឱ្យគណបក្ស ហ៊្វុនស៊ិនប៉ិច ដែលមានព្រះអង្គម្ចាស់ នរោត្តម រណឬទ្ធិ ជាប្រធាន ។ ប៉ុន្តែគួរឱ្យសោកស្តាយកាលនោះគណបក្សប្រជាជនកម្ពុជាមិនព្រម ក៏ត្រូវបានព្រះមហាក្សត្រ នរោត្តម សីហនុ ផ្សះផ្សាចែកអំណាចឱ្យធ្វើរដ្ឋាភិបាលចំរុះ ហើយបង្កឱ្យមានរដ្ឋប្រហារនៅថ្ងៃទី៥-៦ ខែកក្កដា ឆ្នាំ១៩៩៧ ។

ព្រឹត្តិការណ៍បង្ហូរឈាមនៅកណ្តាលទីក្រុងភ្នំពេញនេះ បានធ្វើឱ្យរបបរាជានិយមហ៊្វុនស៊ិនប៉ិច មានការថយចុះ និងបាត់បង់អ្នកគាំទ្រជាបន្តបន្ទាប់ ដែលជាហេតុធ្វើឱ្យប្រជាពលរដ្ឋមានការអស់សង្ឃឹមយ៉ាងខ្លាំង ។

***ទឹកចិត្តរារែករបស់ប្រជាពលរដ្ឋ :**

ជាមួយគ្នានេះដែរ គណបក្ស សម រង្ស៊ី ដែលជាពន្លកប្រជាធិបតេយ្យក្មេងខ្ចី និងជាគណបក្សប្រឆាំងស្រួចស្រាលជាងគេ ក៏ទទួលបាននូវសម្លេងគាំទ្រកាន់តែច្រើនក្នុងរដ្ឋសភា ដែលគេសង្ឃឹមថា អាចដឹកនាំប្រទេសជាតិឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យតាមបែបលោកខាងលិច ។ ប៉ុន្តែគួរឱ្យស្តាយ ចាប់តាំងពីដើមឆ្នាំ២០០៨មកម្ល៉េះ មន្ត្រីជាន់ខ្ពស់របស់គណបក្ស សម រង្ស៊ី បានបោះបង់និន្នាការប្រឆាំង ហើយទៅរួមរស់ជាមួយគណបក្សប្រជាជនកម្ពុជាវិញ ដែលទង្វើនេះត្រូវបានអ្នកសង្កេតការណ៍ជាតិ-អន្តរជាតិថា ស្វែងរកលាភសក្ការៈ ធ្វើឱ្យលទ្ធិប្រជាធិបតេយ្យកាន់តែស្រអាប់ ។

ខណៈពេលការបោះឆ្នោតនាថ្ងៃទី២៧ ខែកក្កដា ជិតឈានមកដល់ប្រជាពលរដ្ឋដែលធ្លាប់តែគាំទ្រទ្រង់ រណឬទ្ធិ និងលោក សម រង្ស៊ី មានការរារែកក្នុងចិត្ត ពីព្រោះអ្នកទាំងពីរពួកគាត់សុទ្ធតែធ្លាប់បោះឆ្នោតឱ្យ ប៉ុន្តែនៅតែមិនអាចដណ្តើមបានជោគជ័យទាំងស្រុង ហើយមិនអាចផ្តួលរំលំកុម្មុយនីស្តផ្តាច់ការបានឡើយ ។

***នយោបាយ និងសង្គម :**

នៅពេលដែលខ្មែរប៉ុស្តិ៍សួរពីបំណងប្រាថ្នានៃការចូលរួមបោះឆ្នោតខាងមុខ លោក ទីម អ៊ីម អាយុ៦៧ឆ្នាំ ជាប្រជាពលរដ្ឋរស់នៅភូមិចុងថ្នល់ខាងលិច សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ បានដកដង្ហើមធំ និងជ្រួញចិញ្ចើម

( តទៅទំព័រទី២១ )

# វត្តខ្មែរ Fresno ទីសក្តិសិទ្ធិសំរាប់ការបន់ស្រន់

**Fresno** ***: រ៉ា ឆាថ***

●●●នៅឯវត្ត Fresno ឈ្មោះវត្តព្រះពុទ្ធសាសនរង្សី មានមនុស្សជាច្រើន មិនថាខ្មែរ, អាមេរិកស្លែនីស ពួកគេបាននាំគ្នាដាក់ចិត្តដាក់កាយជឿជាក់ទៅលើជំនឿបន់ស្រន់បំណងសូមឱ្យសម្រេចនូវការប៉ងប្រាថ្នាពីអ្វី ដែលខ្លួនចង់បានដូចចិត្ត នៅចំពោះមុខ ឬទៅថ្ងៃអនាគត ។

នៅឯវត្ត Fresno ស្ថិតនៅម្តុំភូមិខ្មែរភាគខាងជើង រដ្ឋCalifornia ដែលជាតំបន់មួយសំបូរទៅដោយប្រជាកសិករធ្វើចំការស្រែលាយឡំនឹងជំនួញដូញដូរ ឬធ្វើជាកម្មករផងនោះ ហើយបើទោះបីពួកគេទៅដល់ទីណាក្តី ក៏មិនអាចបោះបង់ ឬឃ្លាតឆ្ងាយពីជំនឿ និងការគោរពប្រតិបត្តិតាមគន្លងព្រះពុទ្ធ


អតីតចៅអធិការវត្ត និងជាអ្នកស្ថាបនិកបានទទួលមរណភាព


តាអាចារ្យ គីម វ៉ន



សាសនាឡើយ ។ ព្រោះការរស់ជាមនុស្សចាំបាច់ត្រូវតែមានអត្តសញ្ញាណជាតិសាសនាប្រចាំខ្លួនគ្រប់ៗគ្នា ។

លោកតាអាចារ្យ គីម វ៉ន អាយុជិត៧០ឆ្នាំ បាននិយាយប្រាប់អ្នកកាសែតខ្មែរប៉ុស្តិ៍យើងនៅចំពោះមុខព្រះភក្ត្រព្រះពុទ្ធបដិមាករក្នុងសាលាឆាន់ឱ្យដឹងថា ព្រោះតែការជឿជាក់របស់មនុស្សទៅលើវត្ថុបារមីស័ក្តិសិទ្ធិនៅក្នុងវត្តនេះហើយ បាននាំឱ្យសេវាកម្មប្រើប្រាស់អ៊ិនធើរណេតប្រើដោយមិនគិតកម្រៃ (Free) ពីស្ត្រីជនជាតិស្លែនីសម្នាក់ឈ្មោះ LISA នាងបានជួយចេញបង់ឱ្យនូវថ្លៃប្រើប្រាស់អ៊ិនធើរណេតសំរាប់វត្ត Fresno នេះ ។

លោកតាអាចារ្យ គីម វ៉ន បន្តថា មូលហេតុបែបនេះក៏ព្រោះតែនាង LISA បានមកកាន់វត្តអារាមអុជធូបបន់ស្រន់ព្រះក្នុងជំនឿសុំឱ្យរកការងារបានធ្វើ ។ ក្រោយមកពីរថ្ងៃនៃការបន់ស្រន់នាង LISA ត្រូវបានក្រុមហ៊ុនចំនួនបីបានហៅនាងទៅធ្វើការស្របពេលគ្នា ដែលពេលនោះហើយនាង LISA កាន់តែមានជំនឿទ្វេរថែមទៀត ជាមួយការសិក្សាស្រាវជ្រាវផ្នែកព្រះពុទ្ធសាសនាផងនោះ ។

យោងតាមសំដីលោកតា វ៉ន អះអាងថា រៀងរាល់ថ្ងៃសីល ឬបុណ្យទានផ្សេងៗ នាង LISA តែងតែមកកាន់


រូបសំណាក់ព្រះពុទ្ធត្រាស់ដឹងនៅក្រោមដើមពោធិព្រឹក្ស

វត្តអារាមធ្វើបុណ្យជា មួយខ្មែរក្នុងភាពស្និតស្នាលរហូតចង់ភ្ជាប់និស្ស័យស្នេហ៍ជាសាច់ជាឈាម ជាមួយប្រុសខ្មែរទៀតផង ។

បញ្ហាកើតការជឿជាក់ក្នុងជំនឿ តាមផ្លូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ នេះដែរ លោកតាអាចារ្យបានឱ្យដឹងដែរថា មានខ្មែរមកពីតាមរដ្ឋផ្សេងៗ ក្នុងសហរដ្ឋអាមេរិក ឬកាណាដា នាំគ្នាធ្វើដំណើរមកកាន់ទីវត្តអារាមព្រះពុទ្ធសាសនារង្សី ដែលអ្នកខ្លះមកធ្វើបុណ្យលាបំណន់ ឬបួងសួងប្រាថ្នា សុំនូវកូន (អ្នកដែលគ្មានកូនសោះ) រីឯអ្នកដែលមានកូនសុទ្ធតែស្រីក៏នាំគ្នាមកសុំឱ្យមានកូនប្រុស រហូតដល់បានសំរេចតាមបំណងពួកគេ ។

ស្ត្រីម្នាក់ឈ្មោះ ដានី មកពីរដ្ឋ Washington State បានប្រាប់យើងថា មានព្រះអង្គខ្មៅមួយអង្គនៅវត្ត Fresno នេះ បាននិមន្តយល់សប្តិប្រាប់ពួកគាត់ថា "បើញោមចង់បានកូនបន្តពូជមើលថែរក្សាទៅថ្ងៃអនាគតសូមញោមទៅកាន់វត្ត Fresno អុចធូបបន់ស្រន់ទៅពិតជាបានតាមបំណងប្រាថ្នាហើយ ព្រោះប្តីប្រពន្ធញោមទាំងពីរជាអ្នកធ្វើបុណ្យទានចេះធ្វើអំពើល្អយល់ដឹងនូវផ្លូវព្រះពុទ្ធសាសនាបានខ្ជាប់ខ្ជួនល្អ" ។

បងស្រី ដានី បានតំណាលថា គាត់ស្ទើរតែពុំជឿសោះ ហេតុអ្វីបានជាព្រះអង្គខ្មៅដែលយល់សប្តិប្រាប់ដឹងថា ខ្ញុំចង់បានកូន ព្រោះខ្ញុំបានគ្នាជាប្តីប្រពន្ធជាង ២០ឆ្នាំមកហើយគ្មានកូនសោះ ។ គាត់បន្តថា រូបគាត់ចង់ទៅពិគ្រោះជាមួយវេជ្ជបណ្ឌិត ដើម្បីរកបច្ចេកទេសតាមបែបវិទ្យាសាស្ត្រឱ្យមានកូនដែរ តែមិនហ៊ានសំរេចចិត្តក៏នៅតាមដំណើរអញ្ជើងរហូតដល់ឆ្នាំ២០០៧ ។ ប៉ុន្តែឥឡូវគាត់មានកូនប្រុស១អាយុមួយខួប ហើយក្នុងឆ្នាំ២០០៨នេះ ការមកកាន់វត្តអារាមនេះ គឺដើម្បីធ្វើបុណ្យដាក់ទានសងបំណុលព្រះរួមជួយកសាងវត្តក្នុងការទ្រទ្រង់វិស័យព្រះពុទ្ធសាសនា ។

ខ្មែរប៉ុស្តិ៍មានការសោកស្តាយដែលបងស្រី ដានី មិនអនុញ្ញាតឱ្យដាក់រូបនៅលើទំព័រកាសែត ដើម្បីជាតឹកតាងដល់មិត្តអ្នកអាន ។

បុរសចំណាស់ម្នាក់អះអាងថា គាត់ជាសមាជិកគណៈកម្មការវត្តនោះនិយាយថា រៀងរាល់ចុងសប្តាហ៍មានបងប្អូនខ្មែរមកពីទីជិតឆ្ងាយមកកាន់វត្ត Fresno នេះមិនដាច់ ដើម្បីធ្វើបុណ្យបួងសួង ឬបន់ស្រន់ប្រាថ្នាសុំនូវអ្វីដែលគេចង់បាន និងមកកាន់ទីនេះ ដើម្បីលាបំណន់ ។ ចំណែកអ្នកខ្លះទៀតក៏និយមទៅឱ្យព្រះសង្ឃស្រោចទឹកមន្ត ដើម្បីលើករាសីផងដែរ ។

បុរសចំណាស់រូបនោះបន្តថា កូនប្រុសរបស់គាត់បានទៅរៀបការប្រពន្ធនៅឯស្រុកខ្មែរ ដើម្បីធានាយកមករួមរស់នៅជាមួយគ្នាជាមិត្ត១០០ឆ្នាំ ។ ប៉ុន្តែការសម្ភាសន៍សុំសិទ្ធិមករស់នៅសហរដ្ឋអាមេរិកពុំបានសម្រេចត្រូវធ្លាក់ រហូតដល់ក្រោយមកក្នុងការដាក់ចិត្តដាក់កាយក្នុងជំនឿបែបមន្តអាគមផ្សំអាយុតាមផ្លូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ គាត់ក៏នាំកូនគាត់មកវត្តស្រោចទឹកមន្ត បន់ស្រន់ចំពោះមុខព្រះពុទ្ធបដិមាករព្រះអង្គខ្មៅ ដោយបួងសួងសុំក្នុងន័យយ៉ាងដូច្នេះថា "ឱគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ព្រះអង្គខ្មៅ និងអ្នកតា វត្ថុសក្តិសិទ្ធិដែលថែរក្សាវត្ត ព្រះពុទ្ធសាសនរង្សី

( តទៅទំព័រទី)

# សម រង្ស៊ី : កង្វល់របស់យើងទុក្ខលំបាករបស់ពលរដ្ឋ និងអន្តោប្រវេសន៍យួនខុសច្បាប់

***ភ្នំពេញ : គីម សារឿន***

●●●គណបក្ស សម រង្ស៊ី ជាគណបក្សប្រឆាំងដ៏ធំបំផុតក្នុងប្រទេសកម្ពុជា ដែលសំបូរទៅដោយអ្នកមានចំណេះដឹងជ្រៅជ្រះ ហើយទទួលបានការគាំទ្រពីសំណាក់មហាជនកាន់តែច្រើន ។ ជាពិសេសនោះ គណបក្ស សម រង្ស៊ី បានទាក់ទាញយុវជនឱ្យគាំទ្រកាន់តែច្រើន ប៉ុន្តែអ្វីដែលគួរឱ្យចាប់អារម្មណ៍ចាប់តាំងពីដើមឆ្នាំ ២០០៨ មក មន្ត្រីជាន់ខ្ពស់នៃគណបក្សនេះបានអូសទាញគ្នាទៅចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា តាមរយៈការសន្យាផ្តល់តួនាទីក្នុងរដ្ឋាភិបាល ។

ខាងក្រោមនេះ គឺជាបទសម្ភាសន៍រវាងខ្មែរប៉ុស្តិ៍ជាមួយនឹងលោក សម រង្ស៊ី ប្រធានគណបក្ស សម រង្ស៊ី ដែលមានខ្លឹមសារដូចតទៅ :

**+តើចលនានៃការចាកចេញរបស់មន្ត្រីជាន់ខ្ពស់គណបក្ស សម រង្ស៊ី ទៅរួមរស់ជាមួយ គណបក្សប្រជាជនកម្ពុជាកាន់តែច្រើន តើបញ្ហានេះបណ្តាលមកពីអ្វី ?**

នេះជាល្បិចរបស់គណបក្សប្រជាជនកម្ពុជា ដើម្បីបង្វែរអារម្មណ៍ប្រជាពលរដ្ឋកុំឱ្យគិតរឿងសំខាន់ៗដែលទាក់ទងទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃកំពុងជួបការលំបាក ហើយយករឿងកំប៉ិកកំប៉ុកមកពូតផ្តុំធ្វើជារឿងធំ ។ ដូច្នេះខ្ញុំសូមអំពាវនាវដល់បងប្អូនទាំងអស់កុំឱ្យចាញ់បោកគេ បើយើងងាកអារម្មណ៍នឹងចាញ់បោកគេហើយ ពីព្រោះ យើងឈប់គិតគូរឿងបញ្ហាជាតិសំខាន់ៗ ដូចជាការបាត់បង់ទឹកដី បំផ្លាញព្រៃឈើ បំផ្លាញត្រី បរិស្ថានពីសំណាក់បរទេសឈ្លានពាន ។

ជាពិសេសនោះ ប្រជាពលរដ្ឋគ្មានការងារធ្វើ ទំនិញឡើងថ្លៃកប់ពពកនេះជាបញ្ហាដែលយើងត្រូវគិតទាំងអស់គ្នា ហើយគណបក្សនីមួយៗ ក៏មានបញ្ហាដែរ តែគេនាំគ្នាដោះស្រាយ ។ ចំណែកឯគណបក្ស សម រង្ស៊ី មិនខ្វះធនធានមនុស្សសំរាប់ ឈរឈ្មោះជំនួសអ្នកដែលចាកចេញ និងមិនខ្វះ អ្នកគាំទ្រនោះដែរ ។



សម រង្ស៊ី

**+មន្ត្រីជាន់ខ្ពស់ដែលគណបក្ស សម រង្ស៊ី ផ្តល់កំណើតឱ្យពេលចាកចេញទៅបានធ្វើការបរិហារបក្សយ៉ាងធ្ងន់ៗ តើលោកយល់ឃើញយ៉ាងណាដែរ ?**

បញ្ហានេះសំរាប់ខ្ញុំមិនសំខាន់នោះទេ បញ្ហាដែលខ្ញុំកំពុងគិតនោះ គឺសុខទុក្ខរបស់ប្រជាពលរដ្ឋដែលកំពុងជួបការលំបាកសព្វបែបយ៉ាង ។ យើងមិនទាន់បានដោះស្រាយឱ្យពួកគាត់ផង ស្រាប់តែនាំគ្នាទៅចូលដៃចូលជើងជាមួយគណបក្សប្រជាជនកម្ពុជា មកធ្វើបាបប្រជាជនទៅវិញ ហើយខ្ញុំគិតថា ពួកគាត់កំពុងតែចាញ់បោកគេបោះបង់ឧត្តមគិតរបស់ខ្លួនចោលដែលខំតស៊ូកន្លងមក ។

**+នៅពេលនេះលោកកំពុងទទួលរងសំពាធ២ គឺការចាកចេញនៃថ្នាក់ដឹកនាំរបស់គណបក្ស សម រង្ស៊ី និងបណ្តឹងរបស់លោក ហោ ណាំហុង តើលោកគិតថា ជាឧបសគ្គសំរាប់លោកក្នុងយុទ្ធនាការបោះឆ្នោតដែរ ឬទេ ?**

បញ្ហាទាំងពីរនេះ វាគ្មានអ្វីសំខាន់សំរាប់ខ្ញុំទេ ហើយខ្ញុំក៏មិនបានគិតទុកក្នុងខួរក្បាលនោះទេ ។ តែងតែខ្វាយខ្វល់ពីខ្ញុំប្រជាពលរដ្ឋ នៅតាមមូលដ្ឋាននានា ដែលខ្វាយខ្វល់រឿងទំនិញឡើងថ្លៃកប់ពពក ដោយសារក្រុមហ៊ុនមួយចំនួនបង្កឡើងប្រហែល២០ក្រុមហ៊ុនប៉ុណ្ណោះ ។ ក្រុមហ៊ុនទាំងនោះ បានធ្វើភ្លៀងផ្គរធ្វើឱ្យទំនិញឡើងថ្លៃប្រជាពលរដ្ឋជួបការលំបាកនៅពេលទៅផ្សារទិញម្ហូបអាហារម្តងៗស្ទើរតែយំមិនចេញ ។

**+តើនៅពេលឃោសនាខាងមុខគណបក្ស សម រង្ស៊ី នឹងលើកយកបញ្ហាអ្វីទៅឃោសនាបោះឆ្នោត ដើម្បីទាក់ទាញប្រជាពលរដ្ឋ ?**

បញ្ហាជីវភាពរស់នៅប្រចាំថ្ងៃការបាត់បង់ដីស្រែចំការ និងផ្ទះសំបែងរបស់ប្រជាពលរដ្ឋ ។ ចំពោះអ្នកដែលបាត់បង់បញ្ហាទាំងនេះ យើងត្រូវតែរកយុត្តិធម៌ប្រគល់ជូនឱ្យពួកគាត់វិញ កុំឱ្យមនុស្ស ខិលខូច ជនផ្តាច់ការ ពុករលួយ អ្នករកស៊ីកេងប្រវ័ញ្ចលើញើសឈាមរបស់អ្នកក្រីក្របន្តទៀត ។

បើគណបក្សប្រជាជនកម្ពុជានៅតែកាន់អំណាចបន្តទៀតនោះ ពេលនេះអ្នកខ្លះបានសេចក្តីសុខនៅឡើយ ហើយគណបក្សនេះនឹងបណ្តោយឱ្យជនខិលខូច និងជនបរទេសមកពី ចិន កូរ៉េ ទិញទឹកដី ពីរដ្ឋាភិបាល ឬមិនដឹងជាប្រគល់ឱ្យ ។ ពេលនេះ ពួកគេបានពុះជ្រៀកកាត់ទឹកដីកម្ពុជាជាដុំៗលក់ខ្ទេចខ្ទីអស់ហើយ ដូច្នេះយើងត្រូវតែការពារទឹកដីយើងឱ្យគង់វិញ ។ មិនយូរមិនឆាប់ បើគណបក្សប្រជាជនកម្ពុជាបន្តកាន់អំណាចនោះ ប្រទេសយើងនឹងជួបការលំបាកកាន់តែខ្លាំង ហើយគណបក្ស សម រង្ស៊ី ប្រឆាំងជាដាច់ខាត ចំពោះទង្វើទាំងអស់នេះ ក្នុងបំណងថែរក្សាការពារកេរដំណែលដូនតាយើងឱ្យគង់វង់ ។

ត្រូវបញ្ឈប់បញ្ហាទំនិញឡើងថ្លៃ និងមិនត្រូវអនុញ្ញាតឱ្យក្រុមដដែលធ្វើអាជីវកម្មផ្តាច់មុខបែបនេះទៀតទេ ។ ពួកគេដំឡើងទំនិញគ្រប់មុខ

( តទៅទំព័រទី២០ )

FreeLife
The Himalayan Goji Company®

the World's Most Powerful
Anti-Aging Food

ចំណីដែលទប់ទល់ជរាភាពដ៏ខ្លាំងជាងគេក្នុងលោក
គឺទឹកផ្លែឈើ "គោជី " នៃព្រៃហេមពាន្ត

HIMALYAN GOJI
Juice

ការសម្ងាត់នៃសុខភាពល្អរបស់ពួកអាស៊ីបានត្រូវរកឃើញ នារជ្ជកាលស្តេចតាំងឆ្នាំ ៨០០ គ.ស ពលរដ្ឋនៃតំបន់មួយនៅព្រៃហេមពាន្តមិនព្រមចាស់-សក់ក៏មិនស-ធ្មេញក៏មិនបាក់-គេថា អ្នកស្រុកបានផឹកទឹកអណ្តូងមួយដែលមានដើម "គោជី "ដុះជុំវិញ គេស្មានថា មានវត្ថុសក្តិសិទ្ធអ្វីមួយជួយថែរក្សាពួកគេ ។ ទើបឥឡូវនេះ គេដឹងថា "គោជី " មានជីវជាតិពិសេសមួយឈ្មោះ POLYSACHARIDES ដែលពុំមាននៅផ្លែឈើឯណាទៀតសោះ ដែលជួយដល់ប្រព័ន្ធការពារខ្លួនរបស់មនុស្សបាន ។






បើចង់បាន Goji មកពិសារសូមជាវតាម www.forever.freelife.com
ឬក៏ទូរស័ព្ទលេខ : (267) 253-3947

SHARE THE SECRET

TIME Magazine wrote :

" this year's breakout (Superfruit ) was the Himalyan Goji Berry, said to be a source of energy and longevity ". To order, please visit the website at : www.forever.freelife.com

Or please call (267) 253-3947 to order

## បាត់ដំបងឥឡូវ មានប្លែក...

ប្រជាពលរដ្ឋ មន្ត្រីរាជការ ដែលមានជំនឿលើវត្ថុស័ក្តិសិទ្ធ ពួកគេតែងនាំគ្នាទៅធ្វើការបន់ស្រន់នៅមុខអ្នកតាដំបងក្រញូងមិនដែលដាច់ទេ ជាពិសេសនៅថ្ងៃសីលមានលក់ផ្កាភ្ញី សត្វសំរាប់លែងពេញបរិវេណនោះ ។

លោក ឃិន សុឃុន បានឱ្យដឹងថា អ្នកតាដំបងក្រញូងមានបារមីខ្លាំងដល់សព្វថ្ងៃនេះ និងមានមនុស្សជឿកាន់តែច្រើន ហើយមនុស្សដែលលេងកន្ទុយលេខ និងទឹកភ្លៀងពេលឈ្នះម្តងៗ គេយកតង្វាយមកថ្វាយ គឺជ្រូកខ្វៃទាំងមូលក៏មានដែរ ។

***ប្រវត្តិខេត្តបាត់ដំបង :**

នៅពេលដែលអ្នកទេសចរធ្វើដំណើរមកពីក្រុងភ្នំពេញ ជិតដល់ទីប្រជុំជនខេត្តបាត់-ដំបង នឹងឃើញរូបសំណាកពណ៌ខ្មៅអង្គុយលុតជង្គង់បែរមុខមកទិសខាងត្បូង ដែលអ្នកផង តែងប្រសិទ្ធិនាមហៅថា "អ្នកតាដំបងក្រញូង" ។ តាមរយៈរឿងព្រេងនិទាន និងការតំណាលរបស់អ្នកស្រុកអះអាងប្រហាក់ប្រ-ហែលគ្នាថា អ្នកតាដំបងក្រញូងនេះមានឈ្មោះល្បីល្បាញ តាំងពីសម័យមហានគរម្លេះ កាលនោះបុរសម្នាក់ដើររកផ្តៅប្រទះដើមរកាខ្មៅហើយយកធ្វើជាដំបងក្រញូង និងមានបារមីខ្លាំង ។

នៅពេលនោះបុរសនោះកើតចិត្តលោភលន់ក៏ដណ្តើមរាជ្យ រួចឡើងគ្រងរាជ្យសម្បត្តិដាក់ឈ្មោះថា "ព្រះបាទដំបងក្រញូង" ។ លុះចំណេរកាលក្រោយមកអ្នកមានបុណ្យឈ្មោះព្រហ្មកិលក៏ជិះសេះសមកអង្គរវត្ត ព្រះបាទដំបងក្រញូងទតឃើញខ្វាល់ក៏ទាញដំបងចោលសំដៅ ប៉ុន្តែមិនត្រូវ ដំបងក៏ធ្លាក់ទៅក្នុងព្រៃខាងក្រោយ គេហៅថា "ព្រៃបាត់ដំបង" ហើយក្រោយមកទីនោះក៏ក្លាយជាទីក្រុងបាត់ដំបងដ៏ល្បីឆើតឆាយរហូតដល់សព្វថ្ងៃ ។



ផ្សារកាត្រីស្របតាមមាត់ស្ទឹងសង្កែក្បែរម្តុំជូចទី ១០ (រូបថតខ្មែរប៉ុស្តិ៍)

នៅសតវត្សទី១៨ដល់ទី២០ បាត់ដំបងបានធ្លាក់នៅក្រោមការត្រួតត្រារបស់សៀមមួយសតវត្ស គ្រប់គ្រងដោយត្រកូលសារចៅហ្វាយ ប៉ែនដាក់ឈ្មោះថា "ត្រកូលអភ័យវង្ស" អស់រយៈ

( តទៅទំព័រទី១៩ )

## នៅក្រោយការបោះឆ្នោតគណបក្ស...

និងមានការសាកសួរដេញដោលពីសំណាក់សមាជិកសភា ។

-មុននឹងសំរេចកិច្ចការដែលទាក់ទងនឹងសន្តិ-សុខជាតិ ឬដែលទាក់ទងនឹងប្រយោជន៍សំខាន់ៗរបស់ជាតិ រដ្ឋាភិបាលត្រូវតែសុំសេចក្តីអនុញ្ញាតពីរដ្ឋសភា ។

-ត្រូវមានមាត្រាមួយចំនួននៅក្នុងរដ្ឋធម្មនុញ្ញផ្តល់អំណាចដល់រដ្ឋសភា ដើម្បីរំលាយរដ្ឋាភិបាល ឬរំលាយខ្លួនឯងក្នុងករណីដែលមានការរំលោភច្បាប់ពីសំណាក់រដ្ឋាភិបាល ឬរដ្ឋសភាខ្លួនឯង ។ ឧទាហរណ៍ក្នុងករណីដែលរដ្ឋាភិបាលខកខានមិនបានមករាយ-ការណ៍ពីរដងជាប់គ្នា ឬក្នុងករណីដែលរដ្ឋសភាបើកសម័យប្រជុំមិនកើតក្នុងរយៈពេលសមស្របណាមួយរដ្ឋាភិបាល ឬរដ្ឋសភាត្រូវតែរំលាយខ្លួនឯងដោយស្វ័យប្រវត្តិ។ នៅមានការផ្តល់ជូនដល់ស្ថាប័ននីតិបញ្ញត្តិនូវ "សិទ្ធិ និងអំណាច" មួយចំនួនទៀត និងការធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ ដើម្បីឱ្យរដ្ឋសភាជាតិក្លាយជាសភាតំណាង "អំណាចប្រជារាស្ត្រ" ពិតប្រាកដ ។ អ្នកជំនាញការច្បាប់ ឬអង្គការក្រៅរដ្ឋាភិបាលនៅប្រទេសកម្ពុជាអាចជួយណែនាំគណបក្សណាដែលមានចេតនាចង់ផ្លាស់ប្តូររូបភាពរដ្ឋសភាជាតិនេះ។

បើសិនណាជារដ្ឋសភាអាណត្តិទី៤នេះ ក្លាយជាសភាដែលជាតំណាង "អំណាចនៃប្រជារាស្ត្រខ្មែរ" ពិតប្រាកដមែននោះ ភាពផ្តាច់ការ អំពើពុករលួយ ភាពអយុត្តិធម៌ ការរំលោភលើរាស្ត្រទន់ ខ្សោយ ។ល។ នឹងថមថយចុះមិនខានឡើយ ជាពិសេសការធ្វើអាណានិគមនិយមបែបថ្មីមកលើប្រជាជាតិខ្មែរពីសំណាក់បរទេសក៏នឹងត្រូវបន្ថយល្បឿនដែរ ។

**ការបង្កើតរដ្ឋាភិបាលតាមបែប "បោះឆ្នោតជាកញ្ចប់ " ត្រូវតែលប់ចោល ព្រោះថានេះ ជាការរំលោភរដ្ឋធម្មនុញ្ញយ៉ាងជាក់ស្តែង ដែលមិនអាចប្រកែកបាន ។**

ផ្ទុយទៅវិញ បើសិនណារដ្ឋសភាទី៤នេះ នៅតែជា "សភាប្រថាប់ត្រា" ដដែលនោះ ៥ឆ្នាំខាងមុខនេះ គឺជាថេរៈវេលាដែលបរទេសចាត់ទុកថាជា "រយៈពេលទីបញ្ចប់" សំរាប់ការបំពេញបំណងគេ ។ ដូច្នេះគណបក្សដែលមានវត្តមាននៅក្នុងសភានៃអាណត្តិទី៤នេះ នឹងត្រូវចារទុកក្នុងប្រវត្តិសាស្ត្រថា ជាអ្នកដែលបាន "ហែរហម" ពួក "ពេជ្ឈាត" ដែលសម្លាប់វាស្នាជាតិខ្មែរនៅនាទីចុងក្រោយនេះ ។

គណបក្សដែលតាំងខ្លួនថា ជាអ្នកនិយមលទ្ធិ-ប្រជាធិបតេយ្យត្រូវតែហ៊ានទាមទារ "សិទ្ធ និងអំណាច" របស់ខ្លួនដើម្បីបំរើប្រជាជាតិខ្មែរ ឱ្យមានប្រសិទ្ធិភាពក្នុងការផ្តល់ជូនរាស្ត្រខ្មែរ នូវសិទ្ធិជាប្រជាពលរដ្ឋ និងជាម្ចាស់នៃអំណាច ដែលមិនត្រូវគេរំលោភជិះជាន់ហើយ និងត្រូវតែទទួលបាននូវភាពចំរើនលូតលាស់ស្មើរៗគ្នាក្នុងគ្របវិស័យ ។ នៅពេលដែលព្រះរាជាណាចក្រកម្ពុជាមានស្ថាប័ននីតិបញ្ញត្តិមួយ ដែលបំរើប្រជាពលរដ្ឋ ដោយពិតប្រាកដ គឺនៅពេលនោះហើយ ដែលឯករាជ្យភាពបូណរភាពទឹកដី សន្តិភាព និងវឌ្ឍនភាព ដែលជាសេចក្តីត្រូវការចាំបាច់នៃប្រជាជាតិនិមួយៗនឹងកើតមានដល់ប្រជាជាតិខ្មែរយើងមិនខានឡើយ ។

**ប្រជាពលរដ្ឋខ្មែរសង្ឃឹមថា រដ្ឋសភាអាណត្តិទី៤ ខាងមុខនេះនឹងផ្លាស់ប្តូរទិសនៃវាស្នាប្រជា-ជាតិខ្មែរឱ្យចៀសផុតពីការនៅក្រោម "អាណា-និគមបែបថ្មី " ពីសំណាក់បរទេស ហើយដែលនឹងអាចនាំឱ្យមានការចំរើនលូតលាស់ជាទូទៅមួយ ដែលនៅពេលនោះ ពលរដ្ឋខ្មែរម្នាក់ៗអាចទទួលផលពីការចំរើននេះ បានដោយឥតរើសមុខ ៕**

**បំរើរដ្ឋាភិបាលមួយដែលជារណបបរទេស គឺជាភាពអាម៉ាស់មុខខ្លាំងជាងគេបង្អស់នៃអ្នកជាតិនិយម !**

## សន្ធិសញ្ញាបំពេញបន្ថែម...

នាថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៦២ និងថ្ងៃទី០៨ មិថុនា ឆ្នាំ១៩៨៤ ទទួលស្គាល់ "ព្រំដែនសព្វថ្ងៃ " របស់កម្ពុជា ដូចត្រូវបានកំណត់ដោយឯកសារខាងលើដែលចំណុចនានា មាននិយាមការប្រាកដប្រជា និងត្រូវបានទទួលស្គាល់ដោយសន្ធិសីទនៃក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ ។ ផ្ទុយទៅវិញ សន្ធិសញ្ញាឆ្នាំ១៩៨៥ បានកំណត់ព្រំដែនគោកកម្ពុជា-វៀតណាម ពីចំណុចប្រជុំព្រំដែនកម្ពុជា-វៀតណាម-លាវ ដោយគ្មានបញ្ជាក់និយាមការ ហើយចុះរហូតទៅដល់សមុទ្រត្រង់ចំណុចមួយដែលគេកំណត់ក្នុងកិច្ចព្រមព្រៀង ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ១៩៨២ ស្តីអំពី "ទឹកប្រវត្តិសាស្ត្រ" ដោយនិយាមការ ១០ំ ៣២ ៤ តាមរយៈទទឹងខាងជើង (Latitude Nord) និង១០៣ំ ៤៨ ២ តាមរយៈបណ្តោយខាងកើត ( Longitude Est) ។

ប៉ុន្តែក្រិត្យនៃរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ១៩៧២ បានចំណុចព្រំដែនហ្នឹង ដោយនិយាមការ ១០ំ ២៥ ២៣ តាមរយៈទទឹងខាងជើង (Latitude Nord) និង១០៤ ២៥ ៦៣ តាមរយៈបណ្តោយខាងកើត ( Longitude Est) ។ ដោយគ្មានរដ្ឋជិតខាងណាមួយបានជំទាស់ទេ ។

៤. ចំណែកឯគោលការណ៍នៃ "ការគ្រប់គ្រងពិត-ប្រាកដ និងការកាន់កាប់របស់ប្រជាពលរដ្ឋច្រើនជំនាន់" វិញ បើគេគិតពីសភាពការណ៍ប្រវត្តិសាស្ត្ររបស់កម្ពុជា និងទំនាក់ទំនងរវាងកម្ពុជា និងវៀត-ណាមតាំងពីក្រោយសន្ធិសីទក្រុងហ្សឺណែវ ឆ្នាំ១៩៤៥មក គឺជាគោលការណ៍នៃសិទ្ធអ្នកខ្លាំងជាងគេ ឬជាសិទ្ធិការកាន់កាប់តាមអំពើចិត្ត" របស់អ្នកនោះប៉ុណ្ណោះ ។ ព្រោះហេតុថា ចាប់ពីពេលផ្ទុះសង្គ្រាមអាមេរិកនៅវៀតណាមភ្លាមកងទ័ពនៃក្រុងហាណូយបានចូលកាន់កាប់គ្រប់គ្រង និងធ្វើអាណានិគមលើកទឹកដីកម្ពុជាផ្នែកខាងកើតជាច្រើនកន្លែង ជាពិសេសនៅស្របតាមបណ្តោយនៃជួរភ្នំអាណ្ណាម ។

នៅខាងត្បូងកងកម្លាំងនៃក្រុងសៃហ្គុងមិនព្រមដកខ្លួនចេញពីកោះជិតខាងឆ្នេរសមុទ្រខ្មែរមានកោះត្រល់ជាអាទិ៍ ។ **នៅមានត**




# គ្រួខខ្មែរក្នុងវិបត្តិសេដ្ឋកិច្ច...

មួយជីវភាពកំពុងដុនដាបដែរ ។ បុរសវ័យចំណាស់នោះបន្តថា បើស្រីស្នេហ៍គាត់អាចតស៊ូនិងគាំទ្រនៅជាមួយគាត់បាន គឺមិនបញ្ហាទេ ។ ហើយបើនាងមិនអាចនៅជាមួយគាត់បានទេ ក៏វាមិនបញ្ហា ធ្វើម្ដេចបើការជួយខ្លួនឯងស្ទើរតែមិនរស់ផង ព្រោះណាមួយត្រូវចំណាយលើខ្លួនឯង. ណាមួយ Child Support កូន , ណាមួយទៀតអនាគតប្រពន្ធថ្មី ។

អ្នកស្រី អ៊ឹម ផល្លា ម្ចាស់ផ្សារ Vinh Heng និយាយថា ការរកស៊ីសព្វថ្ងៃវាពិបាកណាស់ អ្នកទិញជាច្រើនបាត់មុខ ហើយបើទិញម្ហូបអាហារក៏ប្រិតប្រៀងមិនសូវខ្ជះខ្ជាយដែរ ។ ព្រោះពួកគេរកស៊ី និងធ្វើការពុំសូវបានចំណូលខ្ពស់ ហើយអ្នកចំណូលខ្ពស់ក៏ជួបការលំបាក ព្រោះទំនិញឡើងថ្លៃកប់ពពកពេក ។ ដូច្នេះសេដ្ឋកិច្ចគ្រួសារក្នុងជីវភាពប្រចាំថ្ងៃ គេប្រយ័ត្នប្រយែងណាស់ ។

ចំណែកម្ចាស់ក្រុមហ៊ុនភ្នំពេញអ៊ិចប្រេសលក់សំបុត្រយន្តហោះ និងផ្ញើលុយ អ្នកស្រី គន្ធា និយាយថា ភ្ញៀវមកផ្ញើលុយមានមិនដាច់អត់ធ្លាក់ចុះទេ ប៉ុន្តែការផ្ញើលុយទៅស្រុកខ្មែរគ្រាន់តែកាត់បន្ថយពីច្រើនមកតិចតែប៉ុណ្ណោះ ។ ដោយអ្នកស្រី គន្ធា និយាយថា បើទោះបីវិបត្តិសេដ្ឋ-កិច្ចពីទំនិញឡើងថ្លៃយ៉ាងណាក៏ដោយ ក៏គេសង្កេតឃើញថា មនុស្សម្នាជាខ្មែរបានទិញសំបុត្រយន្តហោះទៅលេងស្រុកខ្មែរអត់ឈប់ឈរដែរ ។

វ៉ាន់នី បានប្រាប់ខ្មែរប៉ុស្តិ៍ថា ក្នុងមួយឆ្នាំគាត់ទិញសំបុត្រទៅលេងស្រុងខ្មែរពីរដង ប៉ុន្តែការទៅលេងក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ មិនសូវចាយវាយហ៊ឺហារដូចកាលពី១០ឆ្នាំមុនទេ ព្រោះការរកលុយពិបាកណាស់ ឥឡូវមិនថាធ្វើការ ឬបង្កើតជំនួញជួញដូរនោះ ។

ចៅកែភោជនីយដ្ឋានឋានសួគ៌ថ្មី លោក តាត សារ៉េត និយាយថា ឆ្នាំនេះស្ងាត់ភ្ញៀវមកញ៉ាំ ផឹក ស៊ី រាំលេងកំសាន្ត ដែលធ្វើឱ្យការរកស៊ីមានខាតមានចំណេញ ដោយសារសេដ្ឋកិច្ចធ្លាក់ចុះ មនុស្សរកស៊ីមិនសូវបាន ដូច្នេះជំនួញជួញដូរមានការធ្លាក់ចុះមិនសូវមានភ្ញៀវ បើប្រៀបធៀបកាលពីប៉ុន្មានឆ្នាំមុន រៀងរាល់ចុងសប្តាហ៍មានភ្ញៀវយ៉ាងច្រើនរកតុអង្គុយគ្មាន ។

ពួកអាជីវកររកស៊ីគ្រប់ស្រទាប់ មិនថាអ្នកលក់ ឬទិញផ្ទះ ថៅកែផ្សារ ភោជនីយដ្ឋាន កន្លែងជួលជុលរថយន្ត ហាងដេរ លក់សំលៀកបំពាក់ហាងលក់កុន ខារ៉ាអូខេ ស៊ីឌី វីស៊ីឌី ឌីវីឌី ជាដើមបានប្រាប់ខ្មែរប៉ុស្តិ៍ថា ការរកស៊ីមិនកាក់កបបានបង្ខំចិត្តឱ្យពួកគេបិទមុខរបរ ឬជួល និងលក់បន្ត ដើម្បីទៅរកស៊ី ឬធ្វើការនៅឯតំបន់ផ្សេងៗវិញ ។ នៅតាមផ្លូវថ្នល់ Anaheim ដែលជាក្រុងខ្មែរពោរពេញទៅដោយអ្នកជំនួញខ្មែរត្រសងតាមផ្លូវនោះ គេឃើញតួបជាអគារល្វែងមានការបិទទ្វារ ឬដាក់លក់ ឬជួលជាបណ្ដើរៗ ។

ស្ថានភាពសេដ្ឋកិច្ចនៃជីវភាពបងប្អូនខ្មែរនៅក្រុងឡុងប៊ិចបានចែកជាពីរសណ្ឋាន គឺប្រមាណ ៥០%ដែលរស់នៅក្រោមជំនួយលុយរដ្ឋប្រមាណ ៣០%ជាអ្នកធ្វើការក្រុមហ៊ុន និងការងាររដ្ឋ ចំណែក២០%ជាម្ចាស់ជំនួញបង្កើតមុខរបរដោយខ្លួនឯង ។ ប៉ុន្តែការរស់រានមានជីវិតក្នុងជីវភាពគាប់ប្រសើរ វាអាស្រ័យទៅលើការចេះប្រើងប្រែង និងសមត្ថភាពក្នុងការគ្រប់គ្រងគ្រួសារ និងខ្លួនឯងក្នុងខណៈដែលបញ្ហាវិបត្តិសេដ្ឋកិច្ចកំពុងធ្លាក់ចុះយ៉ាងដូច្នេះ ។ ប៉ុន្តែទោះបីជាវិបត្តិសេដ្ឋកិច្ចក្នុងសង្គមខ្មែរកំពុងតែជួបប្រទះបែបនេះក៏ដោយ មិនមែនមានន័យថា បងប្អូនខ្មែរ... សហគមន៍ខ្មែរឡុងប៊ិច មកពីមិននាំគ្នាជួយជ្រោមជ្រែងនោះទេ ពោលគឺវិបត្តិសេដ្ឋកិចសង្គមអាមេរិកាំងទាំងមូលឯណោះទេ ដែលធ្វើឱ្យយើងរាល់គ្នាជួបការលំបាកនោះ ។ បញ្ហាប្រេងសាំងពីមុនដែលយើងធ្លាប់ឃើញយីហោរបស់ស្ថានីយទីមួយៗដាក់តំលៃត្រឹមតែជាងមួយដុល្លារក្នុងមួយហ្គាល្លុន ។ ក៏ប៉ុន្តែសព្វថ្ងៃនេះបើប្រៀបធៀបទៅសាំងឡើងខ្ពស់៤ដង ពីឆ្នាំមុនៗ ដែលតំលៃជាង៤ដុល្លារ ឬជិត៥ដុល្លារ ក្នុងមួយហ្គាល្លុននោះ ។ ចំណែកឯទំនិញ នៅលើទីផ្សារវិញ ឡើងថ្លៃទ្វេរជាពីរ គួរឱ្យបារម្ភជាពន់ពេកជាឧទាហរណ៍ដូចជា អង្ករធ្លាប់តែមានតម្លៃត្រឹម ២២ ឬ ២៣ ដុល្លារក្នុងមួយការ៉ុង ស្រាប់តែឥឡូវឡើង រហូតដល់ជិត៤០ដុល្លារ ។ បញ្ហាចំណោទជាគំរូនេះ ត្រូវបានអ្នកវិភាគសេដ្ឋកិច្ចអះអាងថា សហរដ្ឋអា-មេរិក មានសង្ឃឹមតិចតួចណាស់ ក្នុងការវិនិច្ឆ័យឱ្យអត្រាទំនិញធ្លាក់ចូលទៅរកសភាពដើមវិញ ។ សព្វថ្ងៃនេះអ្វី ដែលសហរដ្ឋអាមេរិកកំពុងព្រួយបារម្ភនោះ គឺសាំងឡើងថ្លៃពីមួយថ្ងៃទៅមួយថ្ងៃ ដូចជាខ្យល់ព្យុះកំបុតត្បូង ដែលរដ្ឋាភិបាលប៊ូស កំពុងតែលើកជាប្រធានបទក្នុងការរកវិធានការណ៍ដោះស្រាយជាមួយស្ថានការណ៍នយោបាយបោះឆ្នោតជិតខិតចូលមកដល់នោះ ។

បញ្ហានេះបានបង្ខំឱ្យរោងចក្រប្រមាណ២៥កន្លែងត្រូវបានផ្អាកដំណើរការរបស់ខ្លួននៅក្នុងសហរដ្ឋ-អាមេរិក ដែលមានមនុស្សរាប់ពាន់នាក់ ត្រូវបាត់បង់ការងារ ដែលនេះហើយ គឺអ្វីៗត្រូវស្ថិតក្នុងការរស់នៅទៅតាមកាលៈទេសៈរបស់សង្គមសេដ្ឋកិច្ច និងនយោបាយរបស់ប្រ-ទេសជាតិតែប៉ុណ្ណោះ ។

យោងតាមរបាយការណ៍ពីអង្គការប្រេងពិភពលោក OPEC បានអះអាងថា ពិភពលោកទាំងមូលកំពុងជួបបញ្ហាការខ្វះខាតប្រេងប្រើប្រាស់ ដោយអង្គការមួយនេះ បានលើកឡើងថា គ្រាន់តែសហរដ្ឋអាមេរិកមួយត្រូវប្រើប្រាស់ប្រេងមួយភាគ៤លើពិភពលោក ដែលមានទំហំខ្ពស់និងច្រើនជាងគេបង្អស់ ។ ការប្រកាសអាសន្ននេះ បានតម្រូវឱ្យប្រទេសមួយចំនួនជាមហាអំណាចសេដ្ឋកិច្ច ពិសេសសហរដ្ឋអាមេរិកនេះតែម្តងកំពុងរៀបចំផែនការដើម្បីពង្រឹងសេដ្ឋកិច្ចរបស់ខ្លួនទៅថ្ងៃមុខ ដោយរកវិធានការណ៍ថ្មីផលិតប្រេងសាំងដោយខ្លួនឯង ដែលពឹងផ្អែកទៅលើការដាំដំណាំធញ្ញជាតិមួយចំនួនដូចជាពោត សណ្តែក អំពៅ ល្ហុងប្រេង ដំឡូងមីជាដើម ។ ដើម្បីចម្រាញ់ចេញជាប្រេង ឬល្បាយលាយគ្នាជាមួយប្រេងឥន្ធនៈពីក្នុងដីនោះផងដែរ ៕

# ស្រមោលស្នេហ៍ឥតន័យ

១- ស្នេហ៍អូនស្នេហ៍ពិតឥតប្រួលប្រែ
ស្នេហ៍ជួបហើយព្រាត់ឃ្លាតទីទៃ
ជួបហើយម្តេចប្រែជាឥតន័យ
ស្ងាត់បាត់សម្តីធ្លាប់ឆ្លងឆ្លើយ ។
២- កាលស្និទ្ធពាក្យពិតថាស្រឡាញ់
ចំណីមួយម៉ាត់ឥតរំលង
កែវភ្នែកក្តក់ក្តាញ់បាញ់ត្រកង
ឥឡូវប្រែខ្វងធ្វើជាហី ។
៣- គិតទៅរឿងស្នេហ៍មិនទៀងឡើយ
ប្រែប្រួលគេចកែប្រែឥតន័យ
នៅជិតបង្កើយលែងស្រដី
ភ្លេចអស់អ្វីៗធ្លាប់ចរចារ ។
៤- ស្នេហ៍ជាស្រមោលពេលរាត្រី
ស្នេហ៍នាំចុកចាប់ឈឺខ្លោចផ្សា
ដូចផ្សែងបារីលើវេហាស៍
នាំឱ្យឱរ៉ាទុក្ខសែនកង្វល់ ។

***ដោយកញ្ញា : ម៉ៅ ចិន្រ្តា***

# វិស្សមកាលនៅ...

វត្តព្រះពុទ្ធរង្សី គឺជាវត្តតែមួយ ក្នុងចំណោមវត្តបួននៅហ្វីឡាដែលហ្វីយ៉ា ដែលសម្បូរដោយកម្មវិធីសង្គម ដូចជាបង្រៀនពីព្រះពុទ្ធសាសនា ពីវប្បធម៌ ភ្លេង របាំ មានបង្រៀនអក្សរ និងអានភាសាខ្មែរបង្រៀនភាសាអង់គ្លេស...។ល។ ព្រះគ្រូចៅអធិការ រ័ត្ន មុនី រួមដោយគណសង្ឃ និងគ្រហស្ថបានយល់ច្បាស់ពីតួនាទីរបស់វត្តអារាមបានពួតដៃគ្នា មិនត្រឹមតែកសាងព្រះពុទ្ធសាសនាតែប៉ុណ្ណោះទេ គឺគេណែនាំគ្នាឱ្យដើរតាមគន្លងនៃពលរដ្ឋថ្លៃថ្នូរចេះដឹងថែមទៀតផង ៕



ពិធីបំបួសកុលបុត្រក្នុងរដូវក្តៅ នៅវត្តព្រះពុទ្ធរស្សី


## Reasons Why You Want to Put
The Advertisement with the Khmer Post
In Philadelphia

**បុព្វហេតុដែលនាំឱ្យលោកអ្នកផ្សាយពាណិជ្ជកម្មនៅ "ខ្មែរប៉ុស្តិ៍"**

The Khmer Post is the only Cambodian media that available to reach out over 30,000 Cambodian readers who live in Philadelphia.



"ខ្មែរប៉ុស្តិ៍" គឺជាប្រព័ន្ធផ្សព្វផ្សាយខ្មែរតែមួយដែលចែកផ្សាយដល់អ្នកអានខ្មែរប្រមាណ ៣ ម៉ឺននាក់ កំពុងរស់នៅហ្វីឡាដែលហ្វីយ៉ា

One phone call away to grow your business, 20% discount when you sign up for a contract of year by calling this number (267) 253-3947.

លេខទូរស័ព្ទដែលធ្វើឱ្យពាណិជ្ជកម្មលោកអ្នករីកដុះដាល គឺ :
**(267) 253-3947**
យើងខ្ញុំចុះថ្លៃជូន ២០ % បើលោកអ្នកផ្សាយ ១ ឆ្នាំ

**Growing your business. Advertise yourself.**

## បាត់ដំបងឥឡូវ មានប្លែក...

ពេល៦តំណរហូតដល់ឆ្នាំ១៩០៧ កាលណោះ គេហៅថា "បាត់ដំបងសម័យលោកម្ចាស់"។ កេរដំណែលជាច្រើនដែលបានបន្សល់ទុកតាំងពីសម័យនោះ ដល់បច្ចុប្បន្ន ហើយជាសម្បត្តិដ៏មានតំលៃទៀតផង ។

តាមរយៈសន្ធិសញ្ញាបារាំង-សៀម ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩០៧ សៀមបានប្រគល់ខេត្តសៀមរាប បាត់ដំបង សិរីសោភ័ណ ចុងកាល់ និងប៉ែកខាងលើដងទន្លេមេគង្គមកកម្ពុជាវិញ ។

***លក្ខណៈភូមិសាស្ត្រ :**

បាត់ដំបង ជាខេត្តមួយមានវិសាលភាពផ្ទៃដីធំទូលាយ និងបង្កលក្ខណៈងាយស្រួលក្នុងការអភិវឌ្ឍន៍ជីវភាពរស់នៅដែលចែកជា១៣ស្រុក ៩៦ឃុំ និង៧៤១ភូមិ មានប្រជាជនប្រមាណ ២៤.៤៨០គ្រួសារ និងមានជនជាតិចិន ចាម យួន ឥណ្ឌា ឡាវ កួយ ព្នង រស់នៅ ។

ខេត្តដែលសំបូរទៅដោយធនធានធម្មជាតិនេះ ស្ថិតនៅភាគពាយ័ព្យនៃប្រទេស តាមបណ្តោយផ្លូវជាតិលេខ៥ចម្ងាយ២៩១គីឡូម៉ែត្រពីទីក្រុងភ្នំពេញ ដែលនៅភាគខាងជើងជាប់ខេត្តបន្ទាយមានជ័យ ខាងកើតជាប់ខេត្តសៀមរាប បឹងទន្លេ សាបខាងត្បូងជាប់ខេត្តពោធិ៍សាត់ និងខាងលិចជាប់ប្រទេសសៀម ។ ខេត្តនេះគ្របដណ្តប់លើផ្ទៃដី ១.១៦២.២០០ហិកតាក្នុងនោះ ដីដំណាំ ៤១៥.២០០ហិកតា វាលស្រែ ៣១៥.១០០ហិកតា ព្រៃឈើ៤៤៤. ២០០ហិកតា ផ្ទៃដីលិចទឹក១៤៥.៨០០ហិកតា និងដីផ្សេងៗ ២៥៧. ១០០ហិកតា ។

***ការងារកសិកម្ម :**

យោងតាមរបាយការណ៍របស់ក្រសួងកសិកម្មបានបញ្ជាក់ថា វិស័យកសិកម្មនៅខេត្តបាត់ដំបង មានការរីកចំរើនខ្លាំងណាស់ ការដាំស្រូវប្រមាណ២៤៤.០១៤ហិកតា ដែលជាជង្រុកស្រូវដ៏ធំបំផុតរបស់ប្រទេសកម្ពុជា ហើយក្នុង១ឆ្នាំសល់ស្រូវសំរាប់ស្តុកទុកលក់ប្រមាណ ៣០០.០០០តោន រហូតគេបង្កើតភូមិកំពង់សីមា "ជាភូមិវប្បធម៌ដំណាំស្រូវ" ។

ក្រៅពីស្រូវបាត់ដំបងសំបូរដំណាំពោតសណ្តែក ដំឡូងមី ឈើហូបផ្លែ ម៉ាក់ប្រេង ម៉ាក់ប្រាំង ក្រូចផ្លុង មានជាពិសេសក្រូចពោធិ៍សាត់ដែលមានរសជាតិឆ្ងាញ់ត្រូវបានអ្នកស្រុកបាណន់ និងបវេលដាំច្រើន សំរាប់ចែកចាយទូទាំងប្រទេស ។ អ្នកទេសចរជិតឆ្ងាយពេលឆ្លងកាត់ខេត្តនេះតែងទិញក្រូចពោធិ៍សាត់ទទួលទាន និងផ្ញើក្រុមគ្រួសារមិនសូវខកខាននោះទេ ជាភស្តុតាងគេបង្កើតភូមិខ្សាច់ពោយ "ភូមិទេសចរណ៍ចំការផ្លែឈើ " ៕

## បន្ទាយលង្វែកសៀម...

ព្រោះតែចង់បានប្រាក់បាតបន្តិចបន្តួច ដើម្បីចំអែតក្រពះមិនប្លែកពីសម័យលង្វែក អ្នកស្រុកចង់បានប្រាក់ដួងបានបំផ្លាញព្រៃប្ញស្សីខ្ទេចខ្ទីអស់ ។

លោក ផៃ ស៊ីផាន បន្តថា មានអ្នកស្រុក ដែលរស់នៅម្តុំប្រាសាទព្រះវិហារប៉ុន្មាន គ្រួសារបង្កបញ្ហាមិនចេះចប់ដូចជា ទន្ទ្រានដី កាប់ព្រៃឈើធ្វើឱ្យអាជ្ញាធរឈឺក្បាលយ៉ាងខ្លាំង ។ លុះស្រាវជ្រាវទៅទើបដឹងថា ពួកគេបានទទួលលុយពីទាហានឈុតខ្មៅថៃ ដែលនេះជាទង្វើខុសឆ្គងធ្ងន់ធ្ងរ ។

កាលពីខែកុម្ភៈកន្លងមកនេះ នៅពេលប្រាសាទព្រះវិហារ ត្រូវរៀបចំបញ្ចូលជាសម្បត្តិបេតិកភណ្ឌជាតិពិភពលោកនោះ រដ្ឋមន្ត្រីការបរទេសសៀមឈ្មោះ ណុប ផានដុន ប៉ាត់មា បាននិយាយទាំងគ្មានការអៀនខ្មាសថា "បញ្ហាប្រាសាទ ព្រះវិហារជារឿងមួយគួរតែយកចិត្តទុកដាក់ និងមិនត្រូវឱ្យមានការប៉ះទង្គិចគ្នារវាងប្រទេសទាំងពីរនោះទេ" ។

មន្ត្រីរូបនោះ បានបន្តថា "បញ្ហាប្រាសាទព្រះវិហារ ក្រសួងការបរទេសមានតួនាទីរក្សាអធិបតេយ្យភាព និងតំបន់ដែនដីរបស់ជាតិ និងរក្សាមធ្យោបាយពិភាក្សាតាមរយៈការទូត" ។

ការលើកឡើងខាងលើ ត្រូវបានសកម្មជនព្រំដែនទាំងក្នុង និងក្រៅប្រទេសជំទាស់ថា នេះជាការរំលោភលើអធិបតេយ្យភាព និងបូរណភាពទឹកដីគួរឱ្យស្អប់ខ្ពើម ។ កន្លងមកតុលាការអន្តរជាតិក្រុងឡាអេ បានកាត់សេចក្តីថាប្រាសាទព្រះវិហារជារបស់ខ្មែររួចទៅហើយ កាលពីឆ្នាំ ១៩៦២ ។ កន្លងមកយួន និងសៀមនៅតែបន្តរំលោភលើបូរណភាពដែនដីកម្ពុជាទាំងដែន សមុទ្រ និងគោក ក្នុងអំឡុងទសវត្សរ៍ឆ្នាំ៨០ និង៩០ យ៉ាងកំរោល ។ អ្នកដែលលើកយកបញ្ហានេះមកនិយាយត្រូវ ហ៊ុន សែន គំរាមចាប់ដាក់គុកថែមទៀត ដូចជាលោក ម៉ម សូណង់ដូ នាយកវិទ្យុសំបុកឃ្មុំ ដែលសម្ភាសន៍ លោក ស៊ានប៉េងសែ រឿងទំនាស់ដីធ្លី លោក រ៉ុង ឈុន ប្រធានសមាគម គ្រូបង្រៀនឯករាជ្យ និងលោក អៀ ចាន់ណា ត្រូវនិរទេសទៅប្រទេសហ្វាំងឡង់ ។

គួរបញ្ជាក់ថា នៅបរិវេណប្រាសាទព្រះវិហារ ត្រូវបានគេរៀបចំជា៣តំបន់ គឺតំបន់ការពារប្រាសាទ ឬតំបន់ស្នូលទំហំ១.៥៤ហិកតា ។ តំបន់អភិវឌ្ឍន៍ឧទ្យានទេសភាព បរិស្ថាន និងទ្រនាប់ទំហំ២.៦៤២ហិកតា និងតំបន់អភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចទំហំ២.៨២៨ហិកតា ។

តំបន់អភិវឌ្ឍន៍ប្រាសាទព្រះវិហារជាទីសក្ការៈនេះ នឹងអាចសាងសង់សណ្ឋាគារ ផ្ទះសំណាក់ អាហារដ្ឋាន និងសេវាបំរើភ្ញៀវផ្សេងៗទៀត ។

ប្រាសាទព្រះវិហារស្ថិតនៅលើជួរភ្នំដងរែក ក្នុងភូមិស្វាយជ្រុំ ឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ដែលកសាងឡើងនៅសម័យមហានគរសតវត្សទី៩ ដល់១៤ ក្នុងរជ្ជកាលស្តេច៤អង្គគឺ :

**១**-ព្រះបាទយសោវរ័្មនទី១ (គ.ស៨៨៩-៩១០) ព្រះអង្គបានសង់ផ្នែកកណ្តាល និងយកទីនេះធ្វើជារាជធានី ។

**២**-ព្រះបាទសូរ្យវរ័្មនទី១ (គ.ស១០០២-១០៥០) ព្រះអង្គកសាងអគារវែងជិតប្រាសាទកណ្តាលកំពែងព័ទ្ធជុំវិញ និងគោបុរៈបី ។

**៣**-ព្រះបាទជ័យវរ័្មនទី៦ (គ.ស១០៨០-១១០៩) ព្រះអង្គកសាងបណ្ណាល័យ និងផ្នែកផ្សេងៗ ។

**៤**-ព្រះបាទសូរ្យវរ័្មនទី២ (គ.ស១១១៣-១១៥០) ព្រះអង្គកសាងព្រះលាន និងនាគព្រមទាំងសម្ពោធសមិទ្ធផលនានា ។

គេសង្ឃឹមថា ប្រាសាទព្រះវិហារជាទីសក្ការៈនឹងត្រូវបានបញ្ចូលជាសម្បត្តិបេតិកភណ្ឌពិភពលោក នៅខែ កក្កដា ខាងមុខនេះ ៕

## បញ្ហាជុំវិញការបោះឆ្នោត...

គោរពគតិយុត្តិធម៌ទាល់តែសោះ ពីព្រោះតាមធម្មតា នៅក្នុងប្រទេសមួយប្រជាពលរដ្ឋទាំងប្រទេស ត្រូវតែមានសិទ្ធិអំណាចដូចៗគ្នាមេកាន់អំណាចមិនត្រូវមានគំនិតលំអៀងរើសអើងទេ ទើបបានត្រូវតាមពាក្យថា "ប្រជាធិបតេយ្យ" ។

ផ្ទុយទៅវិញ គេបំរើតែបក្សរបស់ខ្លួន ដោយយក អង្គការរដ្ឋទៅប្រើប្រាស់ សំរាប់តែបក្សខ្លួនឯងមួយ ដែលខុសស្រឡះពីគោលការណ៍បន្ទាត់នយោ បាយ និងភារកិច្ចរបស់មេដឹកនាំប្រទេសជាតិ ។

៧. សន្តិសុខ បេក្ខជនបក្ស និងសកម្មជនបក្សប្រឆាំង ត្រូវបានគេគម្រាមកំហែងគ្រប់ពេលវេលា មានបេក្ខជន និងសកម្មជនជាច្រើន ត្រូវបានគេគម្រាបកំហែងហួតដល់មានសម្លាប់អស់ជាច្រើនទៀតផង ។ រួចហើយ អាជ្ញាធរបក្សកាន់អំណាច មិនដែលខ្វល់ខ្វាយស្វែងយកចាប់ជនល្មើសយកមកផ្តន្ទាទោសបានសោះឡើយ ។

ផ្ទុយទៅវិញ សន្តិសុខ បេក្ខជន របស់បក្សកាន់អំណាចបរិបូរគ្រប់ពេលវេលាទៅវិញ ។

៨. ទោះបីបទបញ្ញត្ត ដែល គ.ជ.ប ប្រកាសឱ្យប្រើប្រាស់ ក៏ពុំបានអនុវត្តដោយពេញលក្ខណៈដែរ បក្សកាន់អំណាចរំលោភបំពានបានជានិច្ចចំណែកគណបក្សប្រឆាំងត្រូវរងគ្រោះ និងរងការរើសអើងយ៉ាងជាក់ស្តែង ជាការបង្ហាញឱ្យឃើញថា គ.ជ.ប គិតគូតែលើបក្សកាន់អំណាចតែម្យ៉ាងប៉ុណ្ណោះ ៕

## សម រង្ស៊ី : កង្វល់របស់...

លុះពេលបានលុយច្រើនក៏យកទៅសូកប៉ាន់ពួកមន្ត្រីធំៗ ដើម្បីឱ្យពួកគេអាចរកស៊ីបានយូរ និងការពារសិទ្ធិផ្តាច់មុខ ។ ដូច្នេះយើងត្រូវតែបញ្ចប់បញ្ហានេះ ដោយឱ្យមានការប្រកួតប្រជែងឱ្យបានត្រឹមត្រូវ និងបញ្ចុះតំលៃទំនិញ ដើម្បីឱ្យប្រជាពលរដ្ឋបានស្ងប់ចិត្ត ។

បញ្ហាប្រជាជនគ្មានការងារធ្វើនឹងត្រូវរងគ្រោះដោយសារការរឹបអូសយកដីគ្មានអ្វីរស់នៅជាទីពឹង ។ ជាពិសេសពួកគាត់ភាគច្រើន ទាំងនៅទីក្រុង និងជនបទគ្មានការងារធ្វើសមរម្យសំរាប់ទ្រទ្រង់ជីវភាពយើងយល់ថា មានតែការងារនេះទេ ទើបអាចរស់នៅសមរម្យក្នុងជីវភាពថ្លៃថ្នូរ គឺមិនឱ្យពួកគាត់រំពឹងអំណោយបោកបញ្ឆោតបន្តិចបន្តួចនោះទេ ។ ជាពិសេសត្រូវរៀបចំប្រទេសជាតិឱ្យល្អឡើងវិញ ឱ្យពលរដ្ឋមានការងារធ្វើគ្រប់ៗគ្នា ចំណែកឯអ្នកមានការងារធ្វើ សព្វថ្ងៃមានប្រាក់ខែតិចណាស់ មិនអាចរស់នៅបានស្រួលទេ ។

ការកំចាត់អំពើពុករលួយគ្រប់រូបភាព ដើម្បីយកលុយនេះទៅដំឡើង ឱ្យមន្ត្រីរាជការមានជីវភាពធូរធារបំពេញការងារបានល្អ និងប្រមូលប្រាក់ដាក់ចូលក្នុងឃ្លាំងរដ្ឋ ព្រមទាំងរៀបចំប្រព័ន្ធសុខាភិបាលឱ្យល្អព្យាបាលអ្នកជំងឺមិនបាច់បង់ប្រាក់មិនត្រូវទុកឱ្យអ្នកក្រលំបាក ដូចសព្វថ្ងៃរង់ចាំតែសេចក្តីស្លាប់នោះទេ ។

***ពេលនេះគណបក្ស សម រង្ស៊ី កំពុងតែជួបប្រទះនឹងព្យុះបោកបក់ តើលោកសង្ឃឹមថាអាចដណ្តើមបានជ័យជំនះទេ ?**

នេះគឺជាអន្ទាក់របស់គណបក្សប្រជាជនកម្ពុជាដែលធ្វើការអូសទាញមន្ត្រីមួយចំនួនប៉ុណ្ណោះ សំរាប់គណបក្ស សម រង្ស៊ី នៅតែរឹងមាំដដែល គ្មានអ្វីប្រែប្រួលស្រាំនោះទេ អ្វីដែលយើងត្រូវយកចិត្តទុកដាក់នោះ គឺប្រជាពលរដ្ឋដែលកំពុងជួបការលំបាក ។ ចំណែកអ្នកដែលចង់បានប្រយោជន៍គេអូសទាញបាននោះ ជារឿងបុគ្គលរបស់គេ យើងមិនបានចាត់ទុកជារឿងសំខាន់ឡើយ ។

អ្វីដែលយើងគិតថា ចាំបាច់នោះ គឺអ្វីដែលគណបក្សប្រជាជនកម្ពុជាមិនដោះស្រាយធ្វើឱ្យប្រជារាស្ត្រជួបការលំបាកជនជាតិយួនមករស់នៅខុសច្បាប់លើទឹកដីកម្ពុជានេះជាទុក្ខកង្វល់របស់យើង ។

យើងសង្ឃឹមថា ប្រជាពលរដ្ឋនៅតែគាំទ្រយើង ពួកគាត់មិនគាំទ្របុគ្គលប៉ុន្មាននាក់នោះទេ ។ យើងនៅតែមានទំនុកចិត្តថា ការបោះឆ្នោតខាងមុខនឹងទទួលបានជោគជ័យ ប្រសិនបើការបោះឆ្នោតដោយ សេរីយុត្តិធម៌ និងគ្មានការគំរាមកំហែងការទិញដូរទឹកចិត្តនោះទេ ៕


# ការិយាល័យមេធាវី លិនហ្សេ ដឺរេង
LAW OFFICE OF LINDSAY DOERING



**ទទួលការពារផលប្រយោជន៍លោកអ្នកករណីទូទៅតាមផ្លូវច្បាប់ដូចជា :**

- ករណីបើករបរពាណិជ្ជកម្ម នឹងផ្ទេរប្រាក់ក្នុងមុខជំនួញ
- ករណីទិញលក់អចលនវត្ថុ ដូចជា: ផ្ទះសម្បែង ដីធ្លីជាដើម ។
- ករណីគ្រោះថ្នាក់រថយន្ត ឬគ្រោះថ្នាក់នៅកន្លែងធ្វើការ
- ករណីអន្តោប្រវេសន៍
- ឬករណីឧក្រិដ្ឋកម្ម ។ល។

**ធ្លាប់មានបទពិសោធន៍ខ្ពស់ ផ្តល់សេវាជូនតាមវិជ្ជាជីវៈ ហើយតម្លៃក៏សមរម្យទៀតផង យើងអាចមានអ្នកបកប្រែភាសាជូនលោកអ្នកបាន ។**

General practice law office handling matters in :

Corporations and business transations
Read estate
Car Accidents
Work place injury
Immigration
Criminal fefense
Experienced, professional service and reasonable rate. translator available.

Office: (215) 667-8118 2301 Delancey place, Philadelphia PA 19103
Cell : (215) 840-1364 Email : lindsaydoering@yahoo.com



# ហោរាសាស្ត្រប្រចាំខែ កក្កដា ថ្ងៃទី ០៩_២៣



### ឆ្នាំជូត : (ពពួកទេវតាប្រុស ធាតុទឹក)

រាសីលោកអ្នកខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អណាស់ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ គឺតែងទទួលបាននូវផលសម្រេចជាប់ជានិច្ច ។ លោកអ្នកអាចបណ្តាក់ទុនរកស៊ី ឬក៏ចេញទៅជួញដូរផ្លូវឆ្ងាយ មិនថាផ្លូវគោក ឬផ្លូវទឹកឡើយ គឺប្រកបតែសេចក្តីសុខ ព្រមទាំងអាចរកចំណូលចូលផ្ទះយ៉ាងគាប់ចិត្តទៀតផង ។ ចំពោះគូស្នេហ៍ក្នុងរយៈ ពេលនេះមានការ យល់ចិត្តគ្នាល្អណាស់ ៕



### ឆ្នាំឆ្លូវ : ( ពពួកមនុស្សប្រុស ធាតុដី )

រាសីលោកអ្នកល្អជាធម្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ។ ក្នុងរយៈពេលនេះអ្វីៗ ច្រើនមានការប្រែប្រួលពុំទៀងទាត់ឡើយ ដូច្នេះបើលោកអ្នកមានលក់ដីធ្លី ផ្ទះសម្បែង ឬវត្ថុមានតម្លៃផ្សេងៗ ចូរធ្វើលិខិតស្នាមជាលាយល័ក្ខអក្សរដោយមានចុះហត្ថលេខា ឬផ្តិត-ស្នាមមេដៃឱ្យបានត្រឹមត្រូវទើបទៅថ្ងៃមុខពុំមានបញ្ហាចោទឡើង ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះមានភាពស្និទ្ធស្នាលដូចប្រក្រតី ៕



### ឆ្នាំខាល : ( ពពួកយក្សស្រី ធាតុឈើ )

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបបញ្ហាស្មុគស្មាញច្រើន ។ ក្នុងរយៈពេលនេះ លោកអ្នកត្រូវចេះគ្រប់គ្រងទ្រព្យឱ្យបានគង់វង្ស ជាពិសេសអ្នករកស៊ីជួញដូរហាមបណ្តាក់ទុនរកស៊ីដោយទ្រង់ទ្រាយធំ ឬក៏ឱ្យ អតិថិជនជំពាក់បំណុលច្រើន ព្រោះអាចនឹងខាតបង់ ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះមិន សូវបានសុខកាយសប្បាយចិត្តទេ ព្រោះមានរឿងរកាំរកូសច្រើន ៕



### ឆ្នាំថោះ : ( ពពួកមនុស្សស្រី ធាតុឈើ )

រាសីលោកអ្នកខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អណាស់ ។ ក្នុងរយៈពេលនេះរាល់ឧបទ្រពចង្រៃ និងរាល់ឧបសគ្គត្រូវបានសាបរលាបបាត់ស្រមោលអស់រលីង ដូច្នេះលោកអ្នកអាចរកស៊ីជួញដូរបានពេញដៃ ពេញជើង ហើយទោះជាបានជួបនឹងគូប្រជែងជើងខ្លាំងចេញមកតតាំងក៏មិនភ័យព្រួយដែរ ព្រោះលោកអ្នកអាចយកប្រៀបឈ្នះជានិច្ច ។ រយៈពេលនេះ ចំពោះគូស្នេហ៍ប្រកបតែសេចក្តីសុខក្សេមក្សាន្ត ៕



### ឆ្នាំរោង : (ពពួកទេវតាប្រុស ធាតុមាស)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹមៗ ។ ក្នុងរយៈពេលនេះ ថ្វីត្បិតតែ ទើបឈានចូលឆ្នាំថ្មី ហើយរាល់កិច្ចការងាររកស៊ីនៅជួបនឹងឧបសគ្គខ្លះៗក្តី តែកុំភ័យព្រួយអ្វីឡើយ ព្រោះលោកអ្នកអាចរកដំណោះស្រាយបានជ្រះស្រឡះទាំងអស់ ។ ចំពោះគូស្នេហ៍ ក្នុងរយៈពេលនេះប្រយ័ត្នមានអ្នកទីពាចូលមកជ្រៀតជ្រែក ៕



### ឆ្នាំម្សាញ់ : (ពពួកមនុស្សប្រុស ធាតុភ្លើង)

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបបញ្ហាលំបាកៗច្រើន ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ ចូរមានការប្រុងប្រយ័ត្នជាប់ជានិច្ច ជាពិសេសចំពោះអ្នកជំនួញជួញដូរមុននឹងប្រគល់ ឬទទួលនូវមុខទំនិញសព្វសារពើត្រូវចេះពិនិត្យមើលគុណភាព និងរាប់ចំនួនឱ្យបានត្រឹមត្រូវទើបមិនចាញ់បោកគេ ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះច្រើនពាក់មុខយក្សដាក់គ្នា ៕



### ឆ្នាំមមី : (ពពួកទេវតាស្រី ធាតុភ្លើង)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹមៗ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកអាចរកផលចំណូលបានច្រើនគួរសមក្តី តែពុំមានសល់អ្វីជាដុំកំភួនឡើយ ព្រោះការចាយវាយខ្ជះខ្ជាយខ្លាំងពេក ហើយក៏មិនខុសពីទូកធំក្តោងធំដែរ គឺបានត្រឹមតែចំណាយពេលវេលា និងកម្លាំងឥតអំពើ ។ ចំពោះគូស្នេហ៍ ក្នុងរយៈពេលនេះទាល់តែចេះអត់ធ្មត់ទើបទទួលបានសេចក្តីសុខ ៕



### ឆ្នាំមមែ : (ពពួកទេវតាស្រី ធាតុមាស)

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបការងារអ្វីក៏ដោយ ក៏អាចដំណើរការបានស្រួលដែរ ។ ចំពោះអ្នករកស៊ីជួញដូរក្នុងរយៈពេលនេះនឹងមានទ្រព្យហូរចូលប្រៀបដូចត្រូវឆ្នោត ព្រោះមានទំនិញលក់ចេញ ទិញចូលឥតទំនេរដៃ ។ ចំពោះគូស្នេហ៍ ក្នុងពេលនេះកាន់តែប្រកបដោយភាពផ្អែមល្ហែម ៕



### ឆ្នាំវក : (ពពួកយក្សប្រុស ធាតុដែក)

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបនឹងបញ្ហាលំបាកៗច្រើន ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ ចូរកុំមានការធ្វេសប្រហែសឱ្យសោះ ជាពិសេសចំពោះអាជីវករអ្នករកស៊ីជួញដូរមុននឹងទទួល ឬប្រគល់ទំនិញសព្វសារពើចូរចេះពិនិត្យគុណភាព និងរាប់ចំនួនឱ្យបានត្រឹមត្រូវទើបមិនចាញ់បោកគេ ។ ចំពោះគូស្នេហ៍មានរឿងរកាំរកូសច្រើន ៕



### ឆ្នាំរកា : (ពពួកយក្សប្រុស ធាតុដែក)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ។ ក្នុងរយៈពេលនេះលោកអ្នកនឹងបានជួបនូវគូប្រជែងជើងខ្លាំងចេញមុខមកតតាំង ដូច្នេះចូរចេះរៀបចំជើងព្រួលទុកសម្រាប់ទប់ទល់ជាមុន ទើបមិនលិចលង់ទាន់តែហាមដាច់ខាតការប្រើកម្លាំងបាយដោះស្រាយបញ្ហា ព្រោះវាបានត្រឹមតែខាតបង់ទាំងសងខាងតែប៉ុណ្ណោះ ។ ចំពោះគូស្នេហ៍មានការយល់ចិត្តគ្នាល្អណាស់ ៕



### ឆ្នាំច : ( ពពួកយក្សស្រី ធាតុដី )

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹមៗ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបការងារអ្វីក៏ដោយ ក៏មិនត្រូវធ្វើទាំងចិត្តតក់ក្រហល់ដោយខ្វះការពិចារណានោះឡើយ ព្រោះបើមានការភ្លាំងភ្លាត់តែបន្តិចអាចបង់ខាតផលប្រយោជន៍ច្រើន ។ ចំពោះគូស្វាមីភរិយា ក្នុងរយៈពេលនេះ ចូរប្រយ័ត្នប្រយែងក្រែងមានអ្នកក្រៅមកញុះញង់ ៕



### ឆ្នាំកុរ : (ពពួកមនុស្សស្រី ធាតុទឹក)

រាសីរបស់លោកអ្នកស្រុតចុះយ៉ាងខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបនឹងបញ្ហាស្មុគស្មាញច្រើន ។ ក្នុងរយៈពេលនេះ អ្វីដែលលោកអ្នកត្រូវយកចិត្តទុកដាក់នោះ ចូរប្រយ័ត្នប្រយែងចំពោះជនខិលខូច ដែលនៅក្បែរៗលោកអ្នក ព្រោះពួកគេមានគំនិតប៉ុនប៉ងធ្វើអំពើអាក្រក់ ដោយមិនចេញ-មុខ ដូច្នេះត្រូវមានស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ច ។ ចំពោះគូស្វាមីភរិយាក្នុងរយៈពេលនេះមានរឿងរកាំរកូសច្រើន ៕

## UCC អង្គការមួយបំរើ...

ប៉ុន្តែអ្នកស្រីនៅតែប្តេជ្ញា ដោយមុតមាំក្នុងការបង្ហាញកាយវិការ និងទឹកមុខញញឹមថា "UCC នឹងមិនត្រូវបិទទ្វារ ដែលយើងត្រូវតែស្វះស្វែងរកលុយសុំជំនួយពីសហគមន៍មួយទៅសហគមន៍មួយ ដើម្បីដោះស្រាយបញ្ហានេះឱ្យទាល់តែបាន" ។

អតីតសមាជិកក្រុមប្រឹក្សាភិបាលអង្គការ UCC លោក សុទ្ធ ប៉ាលីន ដែលបានសុំលាឈប់ កាលពីសប្តាហ៍មុនបានប្រាប់ខ្មែរប៉ុស្តិ៍ឱ្យដឹងថា "ខ្ញុំជួយសាទរចំពោះការស្វះស្វែងរកជំនួយគាំទ្រUCC បន្តឱ្យជោគជ័យ ប្រសិនបើអ្នកដឹកនាំថ្មីអាចធ្វើទៅបាន ។ ប៉ុន្តែខ្ញុំហាក់គ្មានជំនឿ ព្រោះយើងជំពាក់គាត់គេច្រើនពេក ដែលមិនអាចដកខ្លួនបាន ដោយយើងគ្មានសង្ឃឹមថា UCC អាចដើរទៅមុខទៀតបាននោះ ។

UCC ជាអង្គការមួយបំរើក្នុងសហគមន៍ខ្មែរឡុងប៊ិច មកជាង៣០ឆ្នាំហើយ ក្នុងចំណោមអង្គការធំៗ២ បន្ទាប់ពីអង្គការ C.A.A នោះ ដែលមានកម្មវិធីដូចជា ការបន្ថែមកម្មវិធីក្រៅសាលារៀន និងសិស្សរៀនធ្លាក់ការចាត់ចែងកម្មវិធីជាមួយក្រុមអភិវឌ្ឍន៍យុវជនកម្មវិធីរីករាយរបស់ មាតាបិតា សេវាសហ-គមន៍តាមរយៈបណ្តាញសុខភាពស្ត្រីខ្មែរការថែរក្សាវប្បធម៌ តាមរយៈរបាំអប្សរាកម្មវិធីបង្រៀនអក្ខរ-កម្មខ្មែរ និងកម្មវិធីផ្សេងៗដទៃទៀត ។

អតីតតារាភាពយន្ត យស បូរណ្ណៈ ដែលបំរើការងារនៅក្នុងសហគមន៍ខ្មែរ UCC បាននិយាយថា មានកម្មវិធីសង្គមកិច្ចជាច្រើន ដែលតម្រូវឱ្យយើងជួយដល់សេវាកម្មបំរើប្រជាជនខ្មែរដូចជា ការបំពេញក្រដាសស្នាមលុយកាក់ Social Security Medical Medicare ដោយមិនគិតកម្រៃ ។ល។ ប៉ុន្តែជាអកុសលប្រសិនបើ UCC ត្រូវបិទទ្វារយើងមានការសោកស្តាយចំពោះសហគមន៍ខ្មែរឡុងប៊ិច ដែលត្រូវបាត់ឱកាសមួយយ៉ាងធំក្នុងការអភិវឌ្ឍន៍សង្គមខ្មែរ តាមរយៈអង្គការមួយនេះ ដែលមានមកជាង៣០ឆ្នាំ ហើយនោះ ។ លោក យស បូរណ្ណៈ បន្តថា សង្គមខ្មែរវាអភ័ព្វ និងបរាជ័យ ព្រោះតែបុគ្គលមនុស្សម្នាក់ ឬពីរនាក់បាននាំគ្នាបំផ្លាញនូវផលប្រយោជន៍រួមនូវអ្វីដែលយើងធ្លាប់តែបានធ្វើជួយបងប្អូនខ្មែរជារៀងរាល់ថ្ងៃ មិនតិចជាង៥០នាក់មក រក UCC ឱ្យជួយសំរួល ឬដោះស្រាយកិច្ចការ ពួកគាត់មិនថាសេវាកម្មសង្គមកិច្ច សាធារណៈការ វប្បធម៌ អក្សសាស្ត្រ សិល្បៈ យុវជន និងកិច្ចការអន្តោប្រវេសន៍ឡើយ គឺយើងជួយ

( តទៅទំព័រទី២៣ )

## ចំណាចឆ្នាំប្រការ....

វិញតាមរយៈស្ថានីយទូរទស្សន៍ និងវិទ្យុទាំង ៣៩ ឱ្យចាស់ដៃតែម្តង ។ នេះយើងមិនគិតដល់កាសែត និងទស្សនាវដ្តីនោះទេ ។

ដោយសារតែគណបក្សប្រជាជនកម្ពុជាគ្រប់គ្រងលើស្ថាប័នគ្រប់វិស័យ ហើយបានប្រើប្រាស់តួនាទីបង្គាប់បញ្ជាលើស្ថាប័នផ្សេងៗ ដើម្បីប្រឆាំងនឹងអ្នករិះគន់ហើយថា បានជ័យជំនះពេលបោះឆ្នោតខាងមុខនេះ ។ ហ៊ុន សែន បានប្រកាសក្នុងពិធីចែកសញ្ញាប័ត្រនៅវិទ្យាស្ថានអប់រំក្រុងភ្នំពេញថា "មិនមានកូតាសំរាប់ផ្តល់ដល់អ្នកនូវតំណែងជាប្រធាន ឬអនុប្រធានសភាទៀតទេ" ។ បើសិនអ្នកឈ្នះអ្នកកាន់កាប់តំណែង ១០០ភាគរយ តែបើខ្ញុំឈ្នះខ្ញុំកាន់កាប់ ១០០ ភាគរយ ។ ចំណែកគណបក្សហ៊ុនស៊ិនប៉ិច និងគណបក្ស សម រង្ស៊ី ខ្ញុំនឹងមិនផ្តល់ឱ្យទៀតទេ គឺគណបក្សប្រជាជនកម្ពុជាកាន់កាប់តែម្នាក់ឯង ។

ក្នុងពេលជាមួយគ្នានេះដែរ ហ៊ុន សែន បាន ធ្វើការរិះគន់ចំពោះលោក សុន ឆ័យ, លោក យឹម សុវណ្ណ តំណាងរាស្ត្រគណបក្ស សម រង្ស៊ី និងទ្រង់ រណឫទ្ធិ យ៉ាងចាស់ដៃតែម្តង ព្រមទាំងបញ្ជាឱ្យ ហុក ឡុងឌី អគ្គ-នគរបាលជាតិធ្វើខ្នោះដៃពណិ មាសសំរាប់ដាក់ថ្វាយទ្រង់ រណឫទ្ធិ ផង បើហ៊ាន យាងចូលស្រុកនោះ ។

ការដែល ហ៊ុន សែន ហ៊ាននិយាយបែបនេះ ពីព្រោះកន្លងមកគណបក្សប្រជាជនកម្ពុជា បានផ្តល់អំណោយដល់ប្រជាពលរដ្ឋបន្តិចបន្តួច ដើម្បីបោះឆ្នោតឱ្យខ្លួន និងផ្តល់អំណាចបុណ្យស័ក្តិដល់អ្នកប្រជាធិបតេយ្យមួយចំនួនឱ្យបោះបង់ការប្រឆាំង ហើយចុះចូលកាន់តែច្រើន ។ ចំណែកឯគណបក្សប្រជាធិបតេយ្យកំពុងតែហែកហួរគ្នា មិនព្រមរួបរួមគ្នាដណ្តើមជ័យជំនះ គិតតែមោទនភាពរៀងៗខ្លួន ធ្វើឱ្យប្រជាពលរដ្ឋស្រងាកចិត្ត និងអស់សង្ឃឹមថែមទៀត ៕

# តើតាម៉ុក បាននិយាយអ្វីខ្លះ...

ដាច់ខាតជាមួយអាខ្មាំងយួន ហើយខ្ញុំជឿថា ពិតជាតស៊ូបានដល់ទីបំផុត ។ ប៉ុន្តែ និយាយយ៉ាងនេះ មិនមែនខ្ញុំជាអ្នកស្នេហាជាតិ ហើយល្មោភសង្គ្រាមនោះទេ តែខ្ញុំស្រឡាញ់សន្តិភាពស្រឡាញ់ប្រជាធិបតេយ្យស្រឡាញ់សិទ្ធិមនុស្សស្រឡាញ់មនុស្សមានសិទ្ធិមិនចូលចិត្តធ្វើផ្អែ និងខ្ញុំបំរើគេទេ ។ ត្រង់នោះហើយ ដែលខ្ញុំតស៊ូៗ ព្រោះបានប្រជាធិបតេយ្យផ្ទាល់ខ្លួន ក៏ដូចជាជាតិរបស់ខ្លួនត្រូវការឯករាជ្យគ្មានឱ្យអ្នកណាមកឈ្លានពាន ។ នេះដែលខ្ញុំជឿថា យើងខ្ញុំតស៊ូបានអត់មានអីដែលថា តស៊ូមិនបាននោះទេ ។ ហើយក៏សូមបញ្ជាក់ជាមួយជាតិ និងអន្តរជាតិឱ្យច្បាស់ម្តងទៀត ខ្ញុំមិនមែនជាអ្នកល្មោភសង្គ្រាមនោះទេ យើងខ្ញុំក៏មិនចូលចិត្តសង្គ្រាមដែរ ប៉ុន្តែអាខ្មាំងយួនអា ហ៊ុន សែន ទេ ដែលវាល្មោភសង្គ្រាម ។ ជាក់ស្តែងថ្ងៃទី០៧ កក្កដា អ្នកណាធ្វើរដ្ឋប្រហារ

មនុស្សស្លានទូតអង់គ្លេសម្នាក់ និងកងខេមរៈភូមិន្ទ អា ហ៊ុន សែន ក្បត់ជាតិនេះម្នាក់ទៀត ។ នេះបញ្ជាក់ថា អា ហ៊ុន សែន វាឥតខ្លាំងទេ ? អ្នកតានៅភ្នំព្រះវិហារ កាច់កទម្លាក់វាហើយ ។

**សំនួរ** : អ្នកដែលផ្តាច់ខ្លួនទៅជាមេធំៗ ឬក៏ជាទាហានធម្មតា ? ហើយធ្លាប់មានឥទ្ធិពលអ្វីខ្លះដែរ នៅក្នុងអន្លង់វែងនេះ ? ពួកគេមានចំនួនប៉ុន្មាននាក់ ដែលចេញទៅនោះ ?

**តាម៉ុម** : ពួកក្បត់ទាំងនោះ សុទ្ធជាអតីតពួកប៉ុល ពត ជាមនុស្សលោភលន់ ពុករលួយអបាយមុខ បៀរបៀ ស្រីស្រា ពិសេសបំផ្លាញ ព្រៃឈើពួកនោះលួចកាប់ឈើលក់ ហើយក៏ត្រូវរដ្ឋបាលភូមិ-ឃុំអន្លង់វែងចាប់ដាក់គុក អាខ្លះរួចពីគុកខ្លះទត្រូវគេដកស័ក្តិមិនសប្បាយចិត្ត ក៏នាំគ្នារត់ចូលសារភាពជាមួយយួន មិនមានឥទ្ធិពលអ្វីទេបែប អាផាន់ នេះ ! ។ ពីជំនាន់ ប៉ុល ពត ក៏វា



តា ម៉ុក កំពុងផ្តល់បទសម្ភាសន៍ជាមួយលោក ពិន សំខុន

កំទេចហ៊ុនស៊ិនប៊ិច និងស្តេចក្រុមព្រះ គឺអា ហ៊ុន សែន និងយួនកំទេចរាជ្យបល្ល័ង្កកំទេចជាតិខ្មែរទាំងអស់ឱ្យរលាយសាបសូន្យ ដើម្បីយួន និង អា ហ៊ុន សែន ធ្វើស្តេចនៅលើទឹកដីកម្ពុជា និងលេបយកកម្ពុជាជារៀងរហូត ។

**ប្រព្តិប័ត្ត ពលរដ្ឋសេរី** លេខ ២០ ឆ្នាំទី ២ ចេញផ្សាយថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៨ នៅតំបន់ ដែលគ្មានការគៀបសង្កត់ ទំព័រទី ៤ :

ត្រង់នេះហើយ ដែលបញ្ជាក់ថា ហ៊ុន សែន ជាមហាឧក្រិដ្ឋមានទោស មិនមែនព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ មិនមែន ហ៊្វុនស៊ិនប៊ិច មានទោសនោះទេ ។



សាកសព ប៉ុល ពត

អា ហ៊ុន សែន បើកតុលាការសឹកកាត់ទោសស្តេចក្រុមព្រះ ជាអំពើអាក្រក់ថោកទាបបំផុត ព្រោះស្តេចក្រុមព្រះជាអ្នករងគ្រោះគ្មានទោសពៃរ៍អ្វីទាំងអស់ ។ អា ហ៊ុន សែន ជាមហាមេចោរលក់ទឹកដីលក់គ្រឿងញៀន ។ ថ្ងៃទី០៧ កក្កដា ឆ្នាំ១៩៧៩ ថ្ងៃទី៣០ មិនា ឆ្នាំ ១៩៩៧ នៅមុខរដ្ឋសភា ជាអំពើឧក្រិដ្ឋ ដែលតុលាការអន្តរជាតិត្រូវតែចាប់ ហ៊ុន សែន យកទៅកាត់ទោសនោះបានវាត្រឹមត្រូវ តាមកំហុសវា ដែលវាបានបំផ្លាញប្រទេសជាយូរមកហើយ ហើយដី ព្រៃឈើ ប្រាង្គប្រាសាទ ។

**សំនួរ** : តើអន្លង់វែងអាចឈរជើងបានទេ នៅពេលនេះ ហើយអាចវាទទីសន្តិសុខបានដល់ណាហើយ ?

**តាម៉ុម** : ពួកក្បត់វាគ្រាន់តែបះបោររត់ទៅចូលយួនមិនមែនវាមកកាន់កាប់អន្លង់វែងអីបានទេ គ្រាន់តែវាធ្វើដំណើរទៅ គឺវាងាប់តាមផ្លូវអស់កម្លាំងទៅហើយ ។ ពិតមានវានាំឱ្យមានការលំបាកខ្លះដែរ ព្រោះវាបំផុសចលនាជាច្រើនក្រុមឱ្យបះបោរកន្លែងនេះខ្លះនោះខ្លះ តែមកដល់សព្វថ្ងៃនេះ យើងបញ្ចប់វាអស់ហើយ នៅតិចតួចណាស់ ដែលកម្លាំងយើងកំពុងតែបោសសំអាត ។ ថ្ងៃមុនអ្នកកាសែតមិនទាន់ចូលដល់អន្លង់វែងផង ត្រូវកំលាំងទ័ពបាញ់រត់ទីណាត់ទីណែង មានរបួសចោលអីវ៉ាន់ខ្ទេចខ្ទីអស់ ។ នៅប្រាសាទព្រះវិហារទៀត ពួកអា ហ៊ុន សែន វាមានទាក់ទងបានមនុស្សខិលខូចខ្លះ ហើយវាហៅឧទ្ធម្ភាចក្រឱ្យទៅចុះត្រូវកងទ័ពស្នេហាជាតិកម្ពុជាយើងបាញ់ទម្លាក់វាទៀត ធ្វើឱ្យរបួសធ្ងន់ចង់ចាប់យកទៅវៃចោលដែរ តែខាងយើងខ្ញុំយល់ថា ខ្មែរដូចគ្នា ក៏យើងខ្ញុំមាននយោបាយសណ្តោសជីវិតវាឱ្យវានៅជាកងទ័ពដដែលជាច្រើនលើកមកហើយ អា ផាន់ នេះ មិនមែនតែម្តងទេ ។ វាជាមេចោរលួចឈើលក់ លួចក្បាល អ្នកតា ចូលចិត្តទាក់ទងឥតច្បាប់ជាមួយខ្មាំងជាច្រើនឆ្នាំហើយ វាជាមេដែលដឹកនាំក្រុមដែលបែកទៅ ។ នៅមានទៀតដែរ កែ ពក ពេជ្រ ចៀម ។ កែ ពក ជាអតីតភូមិភាគឧត្តរជាខ្មែរ អា អៀង សារី បង្កប់យូរមកហើយ នៅក្នុងអន្លង់វែងនេះ ។ ពេជ្រ ចៀម ជាខ្សែបង្កប់យួនឋានៈជាគ្រូនៅអន្លង់វែង ហើយក៏ទាក់ទងជាមួយយួនកន្លងមករៀបខ្សែចារកម្មនៅក្នុងជួរកូនសិស្សបំបះបំបោរកូនសិស្សពីឆ្នាំ១៩៩៣ នាំឱ្យច្របូកច្របល់នៅក្នុងអន្លង់វែងម្តងទៀតហើយ ។

សរុបមកទាំងអស់នេះ ជាមនុស្សយួន ជាដៃជើងយួន មិនមែនជាអ្នកស្នេហាជាតិទេ ហើយក៏មិនមែនជាអ្នកតស៊ូដែរ ។ តែយើងខ្ញុំរក្សាបរិយាកាសសាមគ្គី ទុកឱ្យរស់នៅក្នុអន្លង់វែងនេះ គ្មានចោទបែកាន់ ឬចាប់ចង់អ្វីទេ ។

(នៅមានត)

Nationwide

Insurance & Financial Service

សេវាធានារ៉ាប់រង និងហិរញ្ញវត្ថុ

We offer Cheap Price for Every Client

យើងធ្វើជូនគ្រប់គៀវដោយតម្លៃទាប

Business Liability Insurance ធានារ៉ាប់រងជំនួញលោកអ្នក

Home Insurance ធានារ៉ាប់រងផ្ទះសម្បែង

Health Insurance ធានារ៉ាប់រង សុខភាព

Auto Insurance ធានារ៉ាប់រងរថយន្ត

Life Insurance ធានារ៉ាប់រងជីវិត

Discount 30% when you purchase Home & Auto Insurance

ចុះតម្លៃ ៣០ % បន្ថែមបើលោកអ្នកទិញ ធានារ៉ាប់រង ផ្ទះ និងរថយន្តរួមគ្នា

South Philadelphia office:
600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036

North Philadelphia office:
6603 Bustleton Ave.
Philadelphia, Pa 19149
Tel: (215) 335-2140
Fax: (215) 335-2147

Credent REAL ESTATE

2101 Tyson Ave. Philadelphia, PA 19149
Office # 215-338-5650, Fax # 215-338-5651



Charlie Kien Broker/Owner ABR
charliekien@credent.us

We provide completed Real Estate and Mortgage Services

យើងផ្តល់ជូនលោកអ្នកនូវការទិញ លក់ អចលនវត្ថុគ្រប់យ៉ាង ហើយនឹងធ្វើសេវាហិរញ្ញវត្ថុសម្រាប់អចលនវត្ថុទាំងនោះជូនទៀតផង



> First time home buyer grant up to $7,800 ទិញផ្ទះដំបូងរដ្ឋអាចជួយរហូតដល់ $7,800
> Purchase Home & New Contraction ទិញផ្ទះនឹងសង់ផ្ទះថ្មី
> Refinance វាយតម្លៃអចលនវត្ថុសាជាថ្មី ហើយដកប្រាក់ចំណេញជូន
> Want to sell your house បំណងលក់ផ្ទះ

For more information, please call Charlie Kien

Direct # (267) 688-6626

## UCC អគ្គការមួយបំរើ...

ទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន ដោយមិនគិតពីកម្រៃ ។

អ្នកស្រី Sara Pol-Lim អះអាងថា ក្នុងរយៈកាលចុងក្រោយ១៥ខែ ដែលកាន់កាប់ការងារដោយផ្ទាល់ដៃរបស់គាត់ UCC បានធ្វើឱ្យមានការរីកចំរើននូវទិដ្ឋភាពវប្បធម៌ សង្គមកិច្ច ចម្រុះជាតិជាច្រើន ដែលជាស្ពានតភ្ជាប់រវាងសហគមន៍ខ្មែរ និងសហគមន៍ដទៃទៀត ។ ជាពិសេសនោះ គឺគោលដៅរបស់លោកស្រីចង់ជួយប្រជាជន ដែលស្ថិតនៅក្នុងភាពឯកកោឱ្យជ្រួតជ្រាបចូលរួមសកម្មភាពដ៏ធំធេងរបស់សហគមន៍ និងឱ្យពួកគេស្គាល់នូវករណីយកិច្ចជាម្ចាស់សហគមន៍របស់ខ្លួន ទៅរកការរីកចំរើននៃមូលដ្ឋានសេដ្ឋកិច្ចសង្គមអភិវឌ្ឍន៍វប្បធម៌ជាតិបំណងរក្សាតម្លៃនៃអត្តសញ្ញាណជាតិខ្មែរ ។

ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយគ្មាននរណាម្នាក់ទស្សន៍ទាយបានថា សហគមន៍ UCC ដ៏ធំមួយនេះ អាចបន្តដំណើរជីវិតជាអង្គការ សង្គមមនុស្សធម៌ ដើម្បីសហគមន៍បងប្អូនខ្មែរ នៅឡុងប៊ិច បានទៀតឬយ៉ាងណា ? បើយើងក្រឡេកមើលអតីតកាលតាំងពីអ្នកស្ថាបនិកដឹកនាំជំនាន់លោក ប៊ុក ថន រហូតមកអ្នកជំនាន់ក្រោយៗឃើញថា មានបញ្ហាមិនឈប់ឈរ គឺបញ្ហាពុករលួយលុយកាក់ជម្លោះប្រកាន់បក្សពួកបំរើការងារសង្គមទាញលាយឡំទៅនឹងបញ្ហានយោបាយនៅកម្ពុជា ហាក់មិនគិតប្រ-យោជន៍ប្រជាជនជាធំ រហូតដល់បាត់បង់ម្ចាស់ការដល់ទីបំផុតអស់ទ្រព្យសម្បត្តិរួមជារបស់ខ្មែរទាំងអស់គ្នានូវអគារសហគមន៍ខ្មែរ UCC និងកាន់តែបន្តភាពទន់ខ្សោយជួយដល់សហគមន៍បងប្អូនខ្មែរឡុងប៊ិចទៀតផង ៕

PREMIUM
Mountaire
Fresh Young Chicken

"ម៉ោនធែរ" នឹងផ្តល់សំណាងមួយជីវិតលោកអ្នក-យើងកំពុងតែស្វែងរកអ្នកធ្វើការដ៏ប្រសើរ ក៏ដូចជា លោកអ្នកកំពុងតែចង់បានមុខរបរដ៏ជឿនលឿនមួយ
"ម៉ោនធែរ" ផ្តល់ជូននូវគុណប្រយោជន៍ដូចខាងក្រោម ដើម្បីឱ្យលោកអ្នកចូលរួមជាមួយក្រុមហ៊ុនយើងនៅ មីសបូរ (MILLSBORO , DELWARE )

ឥតយកកំរៃលើ : រកកន្លែងឱ្យមកនៅតំបន់ថ្មី.........DELWARE ដែលវែរ
ឥតយកកំរៃ : ទិញផ្ទះ..............................គ្មានយកតាក់លើថ្លៃលក់
ឥតយកកំរៃ : ផ្តល់កន្លែងរស់នៅកំសាន្ត..........ឆ្នេរសមុទ្រដ៏ល្អស្អាត
ជួយផ្តល់កម្មវិធីអប់រំបន្ថែម........................នៅក្បែរ "បល់ទីម័រ" Baltimore
ជូនដំណើរទៅមក.............................វ៉ាស៊ីនតោនឌីស៊ី នឹងហ្វីឡាដែលហ្វីយ៉ា



ដើម្បីយកប្រយោជន៍ទាំងអស់ ដែលយើងមានមកផ្តល់ជូន :
សូមទូរស័ព្ទរក OWEN ELDER លេខ 302-258 6636
ឬអ៊ីមែល oelder@montaire.com




**Buy now on DVD**

award winning film about a Cambodian American family's story
www.NewYearBaby.net
Phone Order: 877-345-6222
Find out more about Socheata Poeuv's organization Khmer Legacies:
www.KhmerLegacies.org

ទិញនៅទីនេះ

"ទទួលពានរង្វាន់ខ្សែភាពយន្តស្តីអំពីរឿងគ្រួសារខ្មែរ-អាមេរិកាំង
www.NewYearBaby.net លេខទូរស័ព្ទបញ្ជាទិញ (877) 345-6222
បើចង់ដឹងបន្ថែមពីអង្គការ "ខ្មែរឡេហ្គាស៊ី" របស់ សុជាតា ពៅ : www.KhmerLegacies.org

# Lynn Skin Care

Professional Esthetician
215-467-4082

បើមុខជាំ..កើតមុន ឬកើតអាចម៍រុយលើផ្ទៃមុខ !!

**WHITE SHOT**
works magically transforming your skin from dark spots, or freckle to a bright and perfect looking skin.

**WRINKLE SHOT**
The new formula that is long-lasting, And deep-acting wrinkle fighter

**WHITISSIMO PRESSED POWDER**
Gives a soft and translucent look while help brighten your face all day long.

**LIQUID FOUNDATION**
Has a moisturizing texture similar to a brightening moisturizer, resistant to strong sunlight, and covers any blemishes

ហាងថែរក្សាស្បែក លីន

អាចធ្វើឱ្យផ្ទៃមុខអ្នកផ្លាស់ប្តូរទៅជាភ្លឺថ្លា ហើយឃើញសាច់អ្នកម៉ត់ល្អស្អាតឥតខ្ចោះ នេះគឺជាភាពស័ក្តិសិទ្ធិនៃ "ស្បូតអ៊ីវេស័រ" ។
កុំភ្លេចសួររកឱសថថែស្បែកមុខផ្សេងៗទៀត...សំរាប់បំបាត់ស្បែកជ្រីវជ្រួញជាដើម...ហាងយើងខ្ញុំអាចប្តូរឱ្យសម្ផស្សឱ្យមានភាពប្រសើរ ដូចបំណងប្រាថ្នារបស់អ្នកបាន

WHITISSIMO






Sale & Skin Care Consultant: Lynn B. Kong
Open 7 Days A Week: Sun to Thurs: 10 a.m. – 7 p.m. / Fr. & Sat: 10 a.m. – 8 p.m.
1730 Snyder Avenue, Philadelphia, Pa 19145